**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ០៨ សរ

# សារាចរ
## ស្ដីពី
## ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៦-២០២៨ និង ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦

### ១-សេចក្ដីផ្ដើម

១-អនុលោមតាមមាត្រា ៥១ នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៣, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដាក់ចេញនូវសារាចរស្ដីពីប្រតិទិនសម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦ កាលពីថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០២៥ ដែលក្នុងនោះ បានកំណត់អំពីពេលនៃការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ ដែលត្រូវអនុម័តដោយគណៈរដ្ឋមន្ត្រី នៅមុនដំណាច់ខែ មេសា សម្រាប់ជាមូលដ្ឋាននៃការរៀបចំក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ ព្រមជាមួយនឹងការដាក់ចេញនូវសារាចរស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៦-២០២៨ និងការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦ ដើម្បីដាក់ជូន **សម្ដេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** ពិនិត្យ និងសម្រេច នៅក្នុងខែ ឧសភា ឆ្នាំ ២០២៥ នេះ។ ជាក់ស្ដែង, ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យម គឺជាផែនការរយៈពេលមធ្យមកម្រិតយុទ្ធសាស្ត្រ ដែលត្រូវបានរៀបចំតាមអភិក្រមពីលើចុះក្រោម (Top Down) មានភាពប្រទាក់ក្រឡា និងបំពេញឱ្យគ្នាទៅវិញទៅមក រវាងក្របខ័ណ្ឌទាំងពីរនេះ ដែលផ្ដល់ជាទស្សនវិស័យ និងតម្រង់ទិសការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសការគ្រប់គ្រងថវិកាជាតិ ទាំងផ្នែកចំណូល និងផ្នែកចំណាយសម្រាប់រយៈពេលមធ្យម។

២-ផ្អែកលើក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ ដែលទទួលបានការអនុម័តរបស់គណៈអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០២៥ (ត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ), ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ ត្រូវបានរៀបចំដើម្បីលម្អិតក្របខ័ណ្ឌថវិការយៈពេលមធ្យមពីកម្រិតវិស័យ ដែលបានកំណត់នៅក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ ទៅដល់កម្រិតក្រសួង ស្ថាប័ន ដើម្បីផ្ដល់ជាទស្សនវិស័យអំពីលទ្ធភាពថវិការយៈពេលមធ្យម ទាំងផ្នែកចំណាយចរន្ត និងផ្នែកចំណាយមូលធន តាមរយៈការកំណត់ និងដាក់ចេញនូវពិតានចំណាយគោលសម្រាប់រយៈពេល ៣ ឆ្នាំជូនដល់ក្រសួង ស្ថាប័ន ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់អនុវត្តការប្រគល់មុខងារមានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដែលពិតានចំណាយគោលនេះ គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ការដាក់ចេញនូវសារាចរស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៦-២០២៨ និង ការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ២០២៦ ដើម្បីគ្រប់ក្រសួង ស្ថាប័ន មានមូលដ្ឋានច្បាស់លាស់ក្នុងការលើកគម្រោងថវិកានាពេលនេះ។

៣-ដូចនេះ, ផ្អែកលើក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨ និងក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨, **សារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៦-២០២៨ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦** ត្រូវបានដាក់ចេញដើម្បីផ្តល់មគ្គុទ្ទេសបច្ចេកទេសគន្លឹះៗ និងការណែនាំផ្នែកបច្ចេកទេសដល់គ្រប់ក្រសួង ស្ថាប័ន, មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមក្រសួង ស្ថាប័ននីមួយៗ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់ការរៀបចំថវិកាពាក់ព័ន្ធនឹងមុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និង វិស័យអប់រំ) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកា (៣ ឆ្នាំរំកិល) ឆ្នាំ ២០២៦-២០២៨ និង លើកគម្រោងថវិកាឆ្នាំ ២០២៦។

ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨ និង ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ បានកំណត់នូវក្របខ័ណ្ឌគោលនយោបាយ និងសូចនាករសំខាន់ៗ ដូចខាងក្រោម៖

## ២-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

៤-មុនការដាក់ចេញពន្ធគយបដិការរបស់សហរដ្ឋអាម៉េរិក, បើផ្អែកតាមការវាយតម្លៃរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ចេញផ្សាយក្នុងខែ មករា ឆ្នាំ ២០២៥, សេដ្ឋកិច្ចសកលត្រូវបានព្យាករណ៍ថានឹងមានកំណើនក្នុងអត្រា ៣,៣% ដូចគ្នាក្នុងឆ្នាំ ២០២៥ និងឆ្នាំ ២០២៦ ជាមួយនឹងនិន្នាការបោះឆ្ពោះទៅរកវិថីនៃកំណើនសក្តានុពល។ យ៉ាងណាមិញ, ការកើនយ៉ាងឆាប់រហ័សជាងការរំពឹងទុកនៃចរន្តគាំពារនិយម (Protectionist policies) ដែលស្តែងចេញជាពិសេស តាមរយៈការដំឡើងពន្ធគយ (Broad-based tariff hike) និងពន្ធគយបដិការ (Reciprocal tariff) បានធ្វើឱ្យការគិតគូរ និងមូលដ្ឋានសម្មតិកម្មទាំងឡាយនៃការព្យាករសេដ្ឋកិច្ចសកលនាពេលនោះ មិនឆ្លុះបញ្ចាំងពីតថភាពជាក់ស្តែងដែលបាននិងកំពុងកើតឡើង។ ក្នុងន័យនេះ, បើផ្អែកតាមការវាយតម្លៃរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ចេញផ្សាយក្នុងខែ មេសា ឆ្នាំ ២០២៥ នាពេលថ្មីៗនេះ, សេដ្ឋកិច្ចសកលត្រូវបានទាញទម្លាក់មកត្រឹមអត្រាកំណើនប្រមាណ ២,៨% និង ៣,០% ក្នុងឆ្នាំ ២០២៥ និង ២០២៦ ពោលគឺធ្លាក់ក្នុងកម្រិតប្រមាណ ០,៥ និង ០,៣ ពិន្ទុភាគរយរៀងគ្នា ពីការព្យាករ ក្នុងខែ មករា ឆ្នាំ ២០២៥ ដោយសារផលប៉ះពាល់ និងកម្មវិបាកនៃគោលនយោបាយគាំពារនិយម ដែលស្តែងឡើងតាមរយៈការដំឡើងពន្ធគយ និងនាពេលថ្មីៗនេះ ជាពិសេស គឺការដាក់ឱ្យអនុវត្តនូវពន្ធគយបដិការ ដែលផលជះនៃការអនុវត្តពន្ធគយនេះ នឹងកាន់តែផ្តល់កម្មវិបាកជាអវិជ្ជមានមួយកម្រិតថែមទៀតដល់ការប្រើប្រាស់ និងសកម្មភាពវិនិយោគក្នុងស្រុក។ ដូចនេះ, ក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ, ទស្សនវិស័យសេដ្ឋកិច្ចសកលមានទំនោរទៅរកហានិភ័យច្រើនជាងកាលានុវត្តភាព តួយ៉ាងដូចជា៖ (១)-កម្មវិបាកនៃការបន្តកើនឡើងនៃចរន្តគាំពារនិយមរបស់សហរដ្ឋអាម៉េរិក ដែលកំពុងលេចចេញនូវសង្គ្រាមពាណិជ្ជកម្ម, សង្គ្រាមបច្ចេកវិទ្យា និងការហក់ឡើងវិញនៃថ្លៃទំនិញសកល; (២)-ភាពតានតឹងនៃកត្តាភូមិសាស្ត្រនយោបាយ ជាក់ស្តែង ដូចជានៅតំបន់មជ្ឈិមបូព៌ា; (៣)-ការបន្តកើនឡើងសម្ពាធបំណុលសាធារណៈ; (៤)-ការបន្តធ្លាក់ចុះនៃវិស័យអចលនទ្រព្យនៅចិន; និង (៥)-ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ។ យ៉ាងណាមិញ, ការបន្តបន្ធូរបន្ថយគោលនយោបាយរឹតបន្តឹងរូបិយវត្ថុ, ការដាក់ចេញនូវកញ្ចប់អន្តរាគមន៍របស់ប្រទេសចិន និងលទ្ធភាពក្នុងការធ្វើសមាហរណកម្មស៊ីជម្រៅនៃពាណិជ្ជកម្មប្រទេសដទៃផ្សេងពីសហរដ្ឋអាម៉េរិក ក៏នៅតែអាចជាកាលានុវត្តភាព សម្រាប់ទស្សនវិស័យសេដ្ឋកិច្ចសកល និងតំបន់ ផងដែរ។

៥-ដោយឡែក, សេដ្ឋកិច្ចកម្ពុជា នៅមុនពេលសហរដ្ឋអាម៉េរិកប្រកាសដាក់ចេញគោលនយោបាយពន្ធគយបដិការ, ក្រោមក្របខ័ណ្ឌនាពេលនោះ, ត្រូវបានវាយតម្លៃថានឹងបន្តរក្សាបាននូវចលនការរឹងមាំ ជាមួយនឹងអត្រា

កំណើនក្នុងរង្វង់ ៦,៣% ដូចគ្នា សម្រាប់ឆ្នាំ ២០២៥ និងឆ្នាំ ២០២៦ និងប្រមាណ ៦,៥% សម្រាប់រយៈពេលមធ្យមឆ្នាំ ២០២៧-២០២៨។ ក៏ប៉ុន្តែ, ដូចគ្នាទៅនឹងការធ្វើបច្ចុប្បន្នភាពនៃកំណើនសេដ្ឋកិច្ចសកលដែរ, កំណើនសេដ្ឋកិច្ចកម្ពុជា ត្រូវបានវាយតម្លៃជាថ្មីថានឹងថមថយបន្តិចវិញ មកនៅត្រឹម ៥,២% សម្រាប់ឆ្នាំ ២០២៥ និងចំនួន ៥% សម្រាប់ឆ្នាំ ២០២៦ ដោយសារការរំពឹងទុកនូវផលប៉ះពាល់នៃគោលនយោបាយពន្ធគយបដិការលើវិស័យបម្រើការនាំចេញ តួយ៉ាងវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ និងផលជះមកលើវិស័យគាំទ្រកំណើនផ្សេងទៀត ដូចជា វិស័យដឹកជញ្ជូន និងស្តុក និងលក់ដុំ-រាយ។ លើសពីនេះ, ប្រសិនបើស្ថានភាពកត្តាខាងក្រៅវិវត្តទៅកាន់តែអាក្រក់ជាងបច្ចុប្បន្ន ហើយការចរចារវាងកម្ពុជា និងសហរដ្ឋអាមេរិក មិនទទួលបានលទ្ធផលល្អដូចការរំពឹងទុក, កំណើននេះនឹងកាន់តែថមថយបន្ថែមទៀត។ ក្នុងន័យនេះ, ការពន្លឿនការអនុវត្តវិធានការ និងគោលនយោបាយជំរុញភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និងពង្រឹងភាពធន់នៃសង្គម-សេដ្ឋកិច្ច ជាពិសេសការពង្រឹងការអនុវត្តនូវ «**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**» និងការដាក់ឱ្យអនុវត្តនូវ «**កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និងពង្រឹងភាពធន់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច នៅក្នុងបរិការណ៍សកលដែលមានភាពមិនប្រាកដប្រជាខ្ពស់ឆ្នាំ ២០២៥-២០២៨**» និងគោលនយោបាយពាក់ព័ន្ធផ្សេងទៀត នឹងកាន់តែមានសារៈសំខាន់ជាចលករក្នុងការជំរុញល្បឿន និងគាំពារកំណើនសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យម និងវែងខាងមុខ។

៦-កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថា ស្ថិតក្នុងអត្រា ៥% ក្នុងឆ្នាំ ២០២៦ និង ជាមធ្យម ៥,៦% សម្រាប់ឆ្នាំ ២០២៧-២០២៨, ដែលក្នុងនោះ៖ (១). **វិស័យឧស្សាហកម្ម** ត្រូវបានព្យាករថា មានកំណើនក្នុងអត្រា ៧,១% ក្នុងឆ្នាំ ២០២៦ និងក្នុងរង្វង់អត្រា ៧,៤% សម្រាប់រយៈពេលមធ្យម ២០២៧-២០២៨ ដោយសារការបន្តថមថយនៃសន្ទុះកំណើនវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ជាបច្ច័យនៃការប៉ះទង្គិចដោយផ្ទាល់នៃគោលនយោបាយពន្ធគយបដិការមកលើការនាំចេញរបស់កម្ពុជា ខណៈដែលវិស័យផលិតកម្មម្ហូបអាហារ និងផលិតកម្មភេសជ្ជៈបន្តរក្សាបានចលនការ ហើយអនុវិស័យសំណង់បន្តងើបឡើង ប៉ុន្តែក្នុងល្បឿនទាប។ (២). **វិស័យសេវាកម្ម** ត្រូវបានព្យាករថា នឹងមានកំណើនក្នុងអត្រាប្រមាណ ៣,៨% ក្នុងឆ្នាំ ២០២៦ និងប្រមាណ ៤,៤% សម្រាប់រយៈពេលមធ្យម ២០២៧-២០២៨ ដោយសារការបន្តងើបនៃវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ និងសេវាកម្មទេសចរណ៍គាំទ្រផ្សេងទៀត ខណៈដែលអនុវិស័យអចលនទ្រព្យនៅបន្តមានកំណើនទាប។ (៣). **វិស័យកសិកម្ម** ត្រូវបានព្យាករថា នឹងមានកំណើន ១,០% ក្នុងឆ្នាំ ២០២៦ និង ១,២% សម្រាប់ឆ្នាំ ២០២៧-២០២៨ ដោយសារការរំពឹងទុកកំណើនប្រសើរនៃអនុវិស័យដំណាំ និងការបន្តរក្សាស្ថិរភាពកំណើននៃអនុវិស័យនេសាទ ស្របពេលដែលអនុវិស័យចិញ្ចឹមសត្វ ក៏បន្តនិន្នាការងើបវិញសន្សឹមៗ។

**៧**-ជារួម, សេដ្ឋកិច្ចកម្ពុជា ដែលមានទំហំតូចហើយបើកចំហរ និងមានការផ្សារភ្ជាប់កាន់តែខ្លាំងជាមួយនឹងច្រវាក់ផលិតកម្មក្នុងតំបន់ និងពិភពលោក, សម្រាប់រយៈពេលមធ្យមខាងមុខ ជាពិសេសសម្រាប់ឆ្នាំ ២០២៦, បាន និងកំពុងហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាដែលបណ្តាលមកពីកត្តាខាងក្រៅ រួមមាន៖ (១)-ការបន្តកើនឡើងនូវចរន្តគាំពារនិយម (Protectionism) ជាពិសេសប្រទេសមហាអំណាចនានា ដែលស្តែងឡើងតាមរយៈការបន្តដំឡើងឡើងពន្ធគយ (Tariffs) ខ្ពស់ជាងការរំពឹងទុក និងភ្លាមៗជាឧទាហរណ៍, (២)-ភាពតានតឹងនៃកត្តាភូមិសាស្ត្រសេដ្ឋកិច្ច ដែលអាចបន្ទចបង្អាក់ដល់ច្រវាក់ផ្គត់ផ្គង់សកល និងនាំទៅដល់ការកើនថ្លៃទំនិញជាអន្តរជាតិ, (៣)-លទ្ធភាពនៃការថមថយនៃសន្ទុះកំណើនសេដ្ឋកិច្ចប្រទេសជាដៃគូពាណិជ្ជកម្ម និងប្រភពវិនិយោគ ជាពិសេសប្រទេសចិន, (៤)-ការកើនឡើងសម្ពាធបំណុលសាធារណៈ, (៥)-ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ច និង

ពាណិជ្ជកម្ម និង (៦)-ផលប៉ះពាល់កាន់តែធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ។ ទន្ទឹមនេះ, កម្ពុជាក៏នៅតែបន្តប្រឈមនឹងបញ្ហាក្នុងប្រទេស រួមមាន៖ (១)-ការចរចាពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិក អាចនឹងមិនទទួលបានលទ្ធផលល្អដូចការរំពឹងទុក ដែលនាំទៅកការធ្លាក់ចុះយ៉ាងគំហុកនៃការនាំចេញ និងអាចឈានទៅដល់ការបិទរោងចក្រ, (២)-កំណើនយឺតជាងការរំពឹងទុកនៃវិស័យមួយចំនួន តួយ៉ាងដូចជា វិស័យសំណង់ និងអចលនទ្រព្យ ដែលធ្វើឱ្យកំណើនជារួម នៅមានកម្រិតទាប, (៣)-បំណុលឯកជនស្ថិតក្នុងកម្រិតខ្ពស់ និងការបន្តកើនឡើងខ្ពស់នៃឥណទានមិនដំណើរការ (NPL) ដែលអាចប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុ, (៤)-ការគៀរគរចំណូលបន្តមានកំណើនទាប និងការថមថយនៃហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ ដែលដាក់កំហិតដល់លទ្ធភាពក្នុងការធ្វើអន្តរាគមន៍ក្នុងពេលមានវិបត្តិ និង (៥)-ហានិភ័យផ្នែកអាកាសធាតុអាចធ្វើឱ្យផលិតភាពវិស័យកសិកម្មទាប និងការខូចខាតលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ ជាមួយគ្នានេះ, ទន្ទឹមនឹងការកើននៃហានិភ័យខាងក្រៅ និងខាងក្នុង, កម្ពុជាក៏នៅតែបន្តប្រឈមបញ្ហាជារចនាសម្ព័ន្ធផ្ទៃក្នុងមួយចំនួន ដែលទាមទារការពង្រឹងការដ្ឋានកែទម្រង់ស៊ីជម្រៅ ដូចជា៖ (ក)-ល្បឿនយឺតនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច, (ខ)-ថ្លៃដើមធ្វើធុរកិច្ចនៅមានកម្រិតខ្ពស់, (គ)-ភាពមានកម្រិតនៃកិច្ចសម្របសម្រួលពាណិជ្ជកម្ម និងបរិយាកាសធុរកិច្ច, (ឃ)-បរិមាណ និងគុណភាពនៃកម្លាំងពលកម្មជំនាញ មិនទាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារ, (ង)-ភាពមានកម្រិតនៃប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម, និង (ច)-ភាពមានកម្រិតនៃចំណេះដឹង និងជំនាញក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល។

៨-ក្នុងបរិការណ៍នេះ, កិច្ចការកែទម្រង់ជារចនាសម្ព័ន្ធ និងការរៀបចំយន្តការអនុវត្តឱ្យបានច្បាស់លាស់ជាអាទិភាពដ៏ចាំបាច់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ចក្នុងស្រុកឱ្យកាន់តែមានសម្ទុះកាន់តែខ្លាំងក្លា និងដើម្បីបញ្ចៀសនូវផលប៉ះពាល់នៃហានិភ័យនានាទាំងកម្រិតសកលនិងតំបន់។ ដូចនេះ, ជាទិសដៅយុទ្ធសាស្ត្រ និងគោលនយោបាយ, រាជរដ្ឋាភិបាលនៅតែបន្តប្រកាន់ខ្ជាប់នូវអភិក្រមចំនួន ២ នោះគឺ៖ (១)-វិធានការគោលនយោបាយឆ្លើយតបទៅនឹងបញ្ហាបន្ទាន់ចំពោះមុខ និងក្នុងរយៈពេលខ្លីដោយផ្ដោតលើការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការធានាលំនឹងជីវភាពរបស់ប្រជាជន; និង (២)-ទិសដៅវិធានការគោលនយោបាយរយៈពេលមធ្យម និងវែងខាងមុខ ដែលនឹងផ្ដោតលើការដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ ក្នុងការជំរុញការធ្វើពិពិធកម្ម ការលើកកម្ពស់ភាពប្រកួតប្រជែង និងការកសាងភាពធន់ សម្រាប់សង្គម-សេដ្ឋកិច្ចកម្ពុជា។ ស្របតាមអភិក្រមខាងលើនេះ, រាជរដ្ឋាភិបាលបានដាក់ចេញវិធានការគោលនយោបាយ ដូចមានខ្លឹមសារពិស្ដារ នៅក្នុងឯកសារក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨ ដែលរួមមាន៖ (១)-វិធានការគោលនយោបាយដោះស្រាយបញ្ហាចំពោះមុខ, (២)-វិធានការគោលនយោបាយហិរញ្ញវត្ថុសាធារណៈ, (៣)-វិធានការគោលនយោបាយរូបិយវត្ថុ និងហិរញ្ញវត្ថុ, និង(៤)-វិធានការគោលនយោបាយដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ។

៩-ក្នុងរយៈពេលមធ្យមខាងមុខ (២០២៦-២០២៨), **អត្រាអតិផរណា** ត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់ ២,៤% ស្របគ្នាទៅនឹងនិន្នាការរឹងមាំនៃសកម្មភាពសេដ្ឋកិច្ច ក្នុងខណៈដែលថ្លៃទំនិញអន្តរជាតិនៅបន្តមានប្រក្រតីភាព។ ជាមួយគ្នានេះ, **អត្រាប្ដូរប្រាក់ផ្លូវការ (រៀល/ដុល្លារអាមេរិក)** រំពឹងថារក្សាបានក្នុងរង្វង់ជាមធ្យម ៤ ០៥០ រៀល/ដុល្លារអាមេរិក ក្រោមការរំពឹងទុកការវិលត្រលប់ទៅរកប្រក្រតីភាពវិញនៃរូបិយប័ណ្ណដុល្លារ គួបផ្សំនឹងជំហរគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការរក្សាស្ថិរភាពអត្រាប្ដូរប្រាក់។

១០-ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ) ត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់ប្រមាណ -២,៨% នៃ ផ.ស.ស. ដោយសារការរំពឹងទុកការបន្តរក្សាបាននូវសមតុល្យពាណិជ្ជកម្ម ស្របពេលដែលចំណូលពីវិស័យទេសចរណ៍ ក៏បន្តនិន្នាការកើនឡើងជាលំដាប់។ ការនាំចេញ រំពឹងថានឹងបន្តនិន្នាការកើនឡើងក្នុងរយៈពេលមធ្យម បើទោះបីមានការថមថយបន្តិចក្នុងឆ្នាំ ២០២៦ ដែលបន្តជំរុញដោយការនាំចេញផលិតផលកម្មន្តសាល (កាត់ដេរ និងមិនមែនកាត់ដេរ) និងកសិផល។ គួបញ្ជាក់ថា, ក្នុងរយៈពេលមធ្យមខាងមុខ, ការនាំចេញកម្ពុជានឹងកាន់តែមានពិពិធភាព, ទាំងទីផ្សារ និងផលិតផល, តួយ៉ាងផលិតផលកម្មន្តសាលមិនមែនកាត់ដេរ ជាពិសេសលើមុខទំនិញឧស្សាហកម្មយុទ្ធសាស្ត្រ និងមានសក្តានុពល តួយ៉ាងដូចជា គ្រឿងបង្គុំអេឡិចត្រូនិក, សំបកកង់រថយន្ត, គ្រឿងសង្ហារិម និងផលិតផលកសិ-ឧស្សាហកម្មកែច្នៃ ជាដើម។ ទន្ទឹមនេះ, ការនាំចូលក៏មាននិន្នាការដូចគ្នាទៅនឹងការនាំចេញ ពោលគឺមានកំណើនថមថយបន្តិច ក្នុងឆ្នាំ ២០២៦ ប៉ុន្តែមាននិន្នាការកើនឡើងក្នុងរយៈពេលមធ្យមខាងមុខ ដែលគាំទ្រដោយការនាំចូលវត្ថុធាតុដើមសម្រាប់ផលិតកម្ម និងទំនិញប្រើប្រាស់ ដើម្បីបម្រើដល់សកម្មភាពផលិតកម្ម និងឆ្លើយតបទៅនឹងការបន្តកើនឡើងនៃតម្រូវការក្នុងស្រុក។ លំហូរវិនិយោគផ្ទាល់ពីបរទេស ត្រូវបានព្យាករថានឹងបន្តកើនឡើងជាលំដាប់ ក្នុងរង្វង់ជាមធ្យមប្រមាណ ៩,៣% នៃ ផ.ស.ស. ដោយសារកើនឡើងនូវទំនុកចិត្តវិនិយោគ ដែលជាបច្ច័យនៃការបន្តអនុវត្តច្បាប់ និងកម្មវិធីជំរុញវិនិយោគ គួបផ្សំនឹងកិច្ចខិតខំប្រឹងប្រែងក្នុងការបន្តកែលម្អបរិយាកាសវិនិយោគ និងកិច្ចសម្រួលពាណិជ្ជកម្ម។ ក្នុងរយៈពេលមធ្យមខាងមុខ, កម្ពុជារំពឹងថានឹងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបន្តទាក់ទាញវិនិយោគ ទៅក្នុងវិស័យឧស្សាហកម្មយុទ្ធសាស្ត្រ ដែលមានតម្លៃបន្ថែមខ្ពស់ក្នុងសេដ្ឋកិច្ច ស្របតាមគោលដៅរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុង «យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»។ លើសពីនេះ, ទុនបម្រុងអន្តរជាតិ ត្រូវបានព្យាករថានឹងបន្តក្នុងកម្រិតអំណោយផល ដែលមានទំហំសមាមាត្រទៅនឹងការនាំចូលប្រមាណ ៦,៩ ខែ ជាមធ្យម។

## ៣-ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

១១-ផ្អែកលើមូលដ្ឋានក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងការវិវត្តជាក់ស្តែងនៃស្ថានភាពហិរញ្ញវត្ថុសាធារណៈ ក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជាកាន់តែខ្ពស់, គោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់រយៈពេលមធ្យម ឆ្នាំ ២០២៦-២០២៨ ត្រូវបានបន្តរៀបចំឡើងដោយប្រកាន់យកនូវ «**ជំហរគោលនយោបាយពង្រឹងប្រសិទ្ធភាពថវិកាជាជំហាន** (Gradual Fiscal Consolidation Stance)» ដើម្បីធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមធ្យម តាមរយៈការបន្តរក្សានូវតុល្យភាពថវិកា រវាងធនធានថវិការបស់រដ្ឋ និងបន្ទុកថវិការបស់រដ្ឋ និង**ចាប់ផ្តើមកសាងទ្រនាប់ថវិកាជាតិឡើងវិញ** នៅពេលកាលៈទេសៈអនុញ្ញាត។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងបន្តផ្តោតជាសំខាន់លើការបន្តពង្រឹងប្រសិទ្ធភាពថវិកា, ទាំងកម្រិតវិភាជន៍ និងកម្រិតប្រតិបត្តិការ, តាមរយៈការបន្តធ្វើអាទិភាវូបនីយកម្មចំណាយ ដោយក្នុងនោះ ក្របខ័ណ្ឌចំណាយសាធារណៈនឹងត្រូវរៀបចំឡើងដើម្បីតម្រង់ទិសធនធានទៅកាន់មុខសញ្ញាដែលជាអាទិភាពសំខាន់ៗចំពោះមុខ, ជាពិសេសដើម្បីធានាលំនឹងជីវភាពប្រជាជន, លើកកម្ពស់សមធម៌សង្គម, បន្តទ្រទ្រង់ដំណើរការនៃកិច្ចអភិវឌ្ឍសង្គម ព្រមទាំងធានានិរន្តរភាពប្រតិបត្តិការការងាររបស់រាជរដ្ឋាភិបាល ស្របតាមទិសដៅជាយុទ្ធសាស្ត្រដែលបានដាក់ចេញនៅក្នុង «**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**» របស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា។

ដូចនេះ, ជាទិសដៅយុទ្ធសាស្ត្រ និងគោលនយោបាយ, ការជំរុញអនុវត្តឱ្យសម្រេចបានជោគជ័យនូវ «យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១» នៅតែជាអាទិភាពរបស់រាជរដ្ឋាភិបាល ព្រមជាមួយនឹងការត្រៀម

ដាក់ចេញ និងអនុវត្តនូវ «កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និងពង្រឹងភាពធន់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់ឆ្នាំ ២០២៥-២០២៨» សំដៅរួមចំណែកដោះស្រាយបញ្ហាជារចនាសម្ព័ន្ធសំខាន់ៗ។ ក្នុងន័យនេះ, គោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៦-២០២៨ បានកំណត់អាទិភាពសំខាន់ៗ ដូចខាងក្រោម៖

- បន្តការពារសន្តិភាព, ស្ថិរភាពនយោបាយ, សមិទ្ធផលសង្គម និងជំរុញការដោះស្រាយបញ្ហាគ្រោះអាសន្ននានាក្នុងសង្គម ដើម្បីរក្សាសុវត្ថិភាព និងសុខដុមរមនាប្រជាជន;
- បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, រក្សាលំនឹងជីវភាព, គាំពារ និងបង្កើតការងារជូនប្រជាជន, បង្កើនប្រសិទ្ធភាព និងវិសាលភាពនៃការគាំពារសង្គម និងការផ្តល់សេវាសង្គមចាំបាច់នានា;
- បន្តជំរុញពិពិធកម្មសេដ្ឋកិច្ចលើវិស័យគន្លឹះដែលមានស្រាប់ និងអភិវឌ្ឍប្រភពថ្មីនៃកំណើនតាមរយៈការគាំទ្រជាគោលនយោបាយដល់បរិយាកាសប្រកួតប្រជែង, ការជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តគ្រប់ប្រភេទ, ទាំងរឹង និងទន់, និងការអនុវត្តយន្តការហិរញ្ញប្បទាន និងផលិតផលហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់ការវិនិយោគ ដែលបង្កើនតម្លៃបន្ថែមខ្ពស់;
- ជំរុញការអភិវឌ្ឍមូលធនមនុស្ស ដោយការលើកកម្ពស់គុណភាពអប់រំ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព បរិយាប័ន្ន និងភាពធន់, ការបណ្តុះបណ្តាល និងអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងបច្ចេកទេសគ្រប់កម្រិត ដើម្បីគាំទ្រផលិតកម្មដែលមានតម្លៃបន្ថែមខ្ពស់;
- លើកកម្ពស់ភាពជាពលរដ្ឋក្នុងសង្គម, លើកកម្ពស់វប្បធម៌ និងសុខុមាលភាពប្រជាជន សម្រាប់ការត្រៀមខ្លួនជាប្រជាជននៃប្រទេសចំណូលមធ្យមកម្រិតខ្ពស់;
- បន្តជំរុញការលើកកម្ពស់សុខុមាលភាពសង្គម, កសាងភាពធន់នៃសង្គមកម្ពុជា និងបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ក៏ដូចជាផ្តល់សេវាសង្គម ជាពិសេសយកចិត្តទុកដាក់លើវិស័យដែលរងកម្មវិបាកពីការប្រែប្រួលរបបពាណិជ្ជកម្ម;
- បន្តជំរុញការធ្វើបរិវត្តកម្មឌីជីថល ដោយវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងជំរុញការអភិវឌ្ឍបៃតង ដើម្បីកសាងរដ្ឋាភិបាល និងពលរដ្ឋឌីជីថលប្រកបដោយចីរភាព;
- បន្តពង្រឹងអភិបាលកិច្ច និងស្ថាប័ន តាមរយៈការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌; និង
- បន្តលើកស្ទួយវិស័យឯកជន ក្នុងនោះរួមទាំងការគាំទ្រការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈការពង្រឹងការអនុវត្តច្បាប់វិនិយោគថ្មី, ការដាក់ចេញវិធានការលើកទឹកចិត្តជាក់លាក់ និងការកែលម្អបរិយាកាសធុរកិច្ចជាមួយនឹងភាពប្រកួតប្រជែង និងសមភាព។

## ៣.១-ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨

១២-ផ្អែកតាមក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ និងអាទិភាពនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈដែលបានកំណត់ខាងលើ, ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ ត្រូវបានដាក់ចេញក្នុងក្របខ័ណ្ឌតុល្យភាពថវិកា ដូចខាងក្រោម៖

## ក្របខ័ណ្ឌតុល្យភាពថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨

| ភាគរយនៃ ផ.ស.ស. | 2025ច្ប. | 2026ច្ប. | 2027ច្ប. | 2028ច្ប. |
|---|---|---|---|---|
| ចំណូលសរុបថវិការដ្ឋ | **15,31%** | **14,63%** | **14,48%** | **14,43%** |
| ចំណូលចរន្តថវិការដ្ឋ | 14,72% | 14,13% | 14,01% | 13,98% |
| ចំណាយសរុបថវិការដ្ឋ | **18,39%** | **16,83%** | **16,57%** | **16,74%** |
| ចំណាយចរន្តថវិការដ្ឋ | 12,62% | 12,05% | 11,84% | 11,47% |
| ចំណាយមូលធនថវិការដ្ឋ | 5,76% | 4,78% | 4,73% | 5,27% |
| អតិរេកចរន្ត | 2,10% | 2,08% | 2,16% | 2,51% |
| សមតុល្យថវិកា | -3,08% | -2,19% | -2,09% | -2,32% |
| *តម្រូវការហិរញ្ញប្បទាន* | ***4,25%*** | ***3,60%*** | ***3,76%*** | ***3,88%*** |
| *ឱនភាពថវិកា* | 3,08% | 2,19% | 2,09% | 2,32% |
| *ការទូទាត់ការខ្ចី* | 1,18% | 1,20% | 1,25% | 1,14% |
| *ការបង្វិលសងអាករលើតម្លៃបន្ថែម* | 0,00% | 0,20% | 0,42% | 0,42% |
| *ប្រភពហិរញ្ញប្បទាន* | ***4,25%*** | ***3,60%*** | ***3,76%*** | ***3,88%*** |
| *ហិរញ្ញប្បទានក្រៅប្រទេស* | 3,06% | 2,95% | 2,83% | 3,04% |
| *មូលនិធិទ្រទ្រង់ថវិកា* | 0,96% | 0,22% | 0,24% | 0,16% |
| *ការបោះផ្សាយមូលបត្ររដ្ឋ* | 0,24% | 0,23% | 0,28% | 0,26% |
| *ប្រាក់បញ្ញើរាជរដ្ឋាភិបាល* | 0,00% | 0,00% | 0,00% | 0,00% |
| *ការបង្វិលសងអាករលើតម្លៃបន្ថែម* | 0,00% | 0,20% | 0,42% | 0,42% |

ជារួម, ក្របខ័ណ្ឌចំណាយសម្រាប់ឆ្នាំ ២០២៦-២០២៨ ត្រូវបានគ្រោងស្របតាមជំហរគោលនយោបាយដែលបានដាក់ចេញ ដែលឱនភាពថវិកាក្នុងរយៈពេលមធ្យមនឹងមានការរួមតូច ធៀបនឹងឆ្នាំ ២០២៥ ដោយរាជរដ្ឋាភិបាលគ្រោងមិនដកប្រាក់សន្សំមកប្រើប្រាស់, លើកលែងតែក្នុងករណីចាំបាច់បំផុត។

### ៣.១.១-ក្របខ័ណ្ឌចំណូលរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨

១៣-ក្របខ័ណ្ឌចំណូលសរុបថវិការដ្ឋ៖ តាមក្របខ័ណ្ឌតុល្យភាពរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ ខាងលើ, ចំណូលសរុបថវិការដ្ឋក្នុងឆ្នាំ ២០២៦ ត្រូវបានកំណត់ថានឹងសម្រេចបានក្នុងទំហំប្រមាណ ១៤,៦៣% នៃ ផ.ស.ស. គឺកើនប្រមាណ ២,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥ ក្នុងនោះ៖

- <u>ចំណូលចរន្តថវិការដ្ឋ</u> ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ១៤,១៣% នៃ ផ.ស.ស., គឺកើនក្នុងរង្វង់ ៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥ ក្នុងនោះ៖

➢ ចំណូលសារពើពន្ធថវិការដ្ឋ ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ១២,១៧% នៃ ផ.ស.ស., គឺកើនក្នុងរង្វង់ ២,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥ ក្នុងនោះ : ប្រមូលដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ៥,២៤% នៃ ផ.ស.ស., និងចំណូលប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ៦,៩៣% នៃ ផ.ស.ស.

➢ ចំណូលមិនមែនសារពើពន្ធថវិការដ្ឋ ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ១,៩៥% នៃ ផ.ស.ស., គឺកើនក្នុងរង្វង់ ៩,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥។

- **ចំណូលផ្សេងៗ** ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ០,៥១% នៃ ផ.ស.ស., គឺថយក្នុងរង្វង់ ៦,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥។

**ចំណូលសរុបថវិការដ្ឋ ក្នុងរយៈពេលមធ្យមឆ្នាំ ២០២៧-២០២៨ ត្រូវបានរំពឹងថាសម្រេចបានកំណើនជាមធ្យម ក្នុងអត្រា ៧,៣% និងស្ថិតក្នុងទំហំ ១៤,៤៣% នៃ ផ.ស.ស. ត្រឹមឆ្នាំ ២០២៨។** ក្នុងនោះ, ចំណូលចរន្តថវិការដ្ឋ ត្រូវបានរំពឹងថាសម្រេចបានកំណើនជាមធ្យម ក្នុងអត្រា ៧,៥% និងស្ថិតក្នុងរង្វង់ ១៣,៩៨% នៃ ផ.ស.ស. ត្រឹមឆ្នាំ ២០២៨ ដែលក្នុងនោះ ចំណូលប្រមូលដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវបានរំពឹងថានឹងសម្រេចបានជាមធ្យមក្នុងអត្រា ៦,៥%, ខណៈចំណូលប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ ត្រូវបានព្យាករថានឹងសម្រេចបានកំណើនជាមធ្យមក្នុងអត្រា ៧,២%។ ជាមួយគ្នានេះ, ចំណូលមិនមែនសារពើពន្ធ ត្រូវបានរំពឹងថាសម្រេចបានកំណើនជាមធ្យមក្នុងអត្រា ១១,២% និងស្ថិតក្នុងរង្វង់ ២,០៧% នៃ ផ.ស.ស. ត្រឹមឆ្នាំ ២០២៨ ជាមួយនឹងការបន្តពង្រឹងការកៀរគរចំណូលពីប្រភពដែលនៅមានសក្តានុពល, ស្របពេលដែលចំណូលពីសម្បទានរ៉ែ វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ផលទុនសកម្មភាពទេសចរណ៍ អាករស្ថានទូត និងផលទុនរបស់អាកាសចរស៊ីវិល ត្រូវបានរំពឹងទុកថានឹងបន្តរើបឡើង។

ដើម្បីសម្រេចគោលដៅចំណូលសរុបខាងលើនេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវផ្តោតការយកចិត្តទុកដាក់លើការជំរុញ និងការពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានជាធរមាន តាមរយៈការអនុវត្តវិធានការម៉ឺងម៉ាត់ និងមុតស្រួច ទាំងវិធានការរដ្ឋបាល និងវិធានការគោល-នយោបាយ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ក្នុងផ្នែកពន្ធដារ ផ្នែកគយនិងរដ្ឋាករ និងផ្នែកចំណូលមិនមែនសារពើពន្ធ ដូចខាងក្រោម៖

- **វិធានការដែលនឹងត្រូវអនុវត្តដោយអគ្គនាយកដ្ឋានពន្ធដារ រួមមាន៖**
  - បង្កើនប្រសិទ្ធភាព និងយន្តការនៃការស៊ើបអង្កេតបទល្មើសពន្ធដារ តាមរយៈការអនុវត្តសៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌពីពន្ធដារ និងបែបបទ និងនីតិវិធីនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌស្តីពីពន្ធដារ (SOP on Investigation) ដើម្បីធានាឱ្យមាននូវតម្លាភាព និងធានានូវការប្រកួតប្រជែងស្មើភាពគ្នា និងបង្កើតឱ្យមានភាពជឿទុកចិត្តពីសាធារណជន ក៏ដូចជាពង្រឹងប្រសិទ្ធភាពនៃយន្តការ ឬប្រព័ន្ធផ្តល់មតិយោបល់ (Feedback Mechanism) ពីអ្នកជាប់ពន្ធ ដែលអាចធានាបាននូវភាពសម្ងាត់នៃឯកជនភាព ទំនុកចិត្តខ្ពស់ និងឆ្លើយតបដល់អ្នកជាប់ពន្ធ;
  - បន្តជំរុញ និងលើកទឹកចិត្តអ្នកជាប់ពន្ធឱ្យមកចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត, ជាពិសេសសហគ្រាសធុនតូច និងមធ្យម;
  - បន្តសិក្សា និងរៀបចំអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល ដើម្បីត្រៀមអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល;
  - អនុវត្តសាកល្បងនូវប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិក (E-invoicing system) ដោយ៖ (១). សិក្សាស្វែងយល់ពីភាពជាដៃគូរជាមួយវិស័យឯកជន ដើម្បីអនុវត្តប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិក ដែលសម្រួលដល់ការរាយការណ៍ និងសុពលភាពប្រតិបត្តិការទាន់ពេល; និង (២). រៀបចំ

លិខិតបទដ្ឋានគតិយុត្ត និងឯកសារណែនាំគ្រប់ជ្រុងជ្រោយ ដើម្បីដាក់ឱ្យដំណើរការសាកល្បងនូវវិក្កយបត្រអេឡិចត្រូនិក;

- ចូលរួមអនុវត្តវិធានការពាក់ព័ន្ធនឹងពន្ធដារ ចំពោះការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីជំរុញវិស័យទាំងនោះឱ្យចូលក្នុងប្រព័ន្ធ ព្រមទាំងលើកទឹកចិត្ត និងថែរក្សាឱ្យវិស័យទាំងនោះក្លាយជាមូលដ្ឋានចំណូលពន្ធបន្ថែម;
- ពង្រឹងយន្តការនៃការអនុវត្តប្រព័ន្ធបង្វិលសងអាករលើតម្លៃបន្ថែម ដើម្បីលើកកម្ពស់ និងធានានូវប្រសិទ្ធភាព ក្នុងការស្នើសុំជាតុចូលអាករលើតម្លៃបន្ថែមលើការកាត់បន្ថយរយៈពេល និងចៀសវាងការយោងឥណទានអាករលើតម្លៃបន្ថែមលើសលប់ក្នុងរយៈពេលយូរ;
- បន្តជំរុញលើការងាររៀបចំការចរចា និងពង្រីកវិសាលភាពនៃកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នា (DTA);
- ពង្រឹងការប្រមូលចំណូលពន្ធ ជាពិសេសអាករលើតម្លៃបន្ថែម លើការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក;
- សិក្សាអំពីលទ្ធភាពក្នុងការដាក់ឱ្យអនុវត្តប្រព័ន្ធ Self-service ជាមគ្គុទេសក៍សម្រាប់អ្នកជាប់ពន្ធ ដើម្បីអាចផ្តល់លទ្ធភាពដល់អ្នកជាប់ពន្ធ ដែលបានចុះបញ្ជីក្នុងប្រព័ន្ធពន្ធដារ អាចដឹងពីប្រភេទពន្ធអាករដែលខ្លួនត្រូវបង់ តាមដានទិន្នន័យបំណុលពន្ធ ដឹងពីស្ថានភាពនៃការចុះធ្វើសវនកម្ម និងទិន្នន័យផ្សេងៗទៀត;
- បន្តរៀបចំជាទៀងទាត់នូវការសិក្សាលើកម្រិតនៃការពេញចិត្តអ្នកជាប់ពន្ធ (Satisfaction survey) លើសេវាអ្នកជាប់ពន្ធ ដើម្បីកែលម្អសេវាកម្មអ្នកជាប់ពន្ធ;
- បន្តលើកកម្ពស់សេវាអ្នកជាប់ពន្ធ ជាពិសេសឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលដោយបន្តធ្វើទំនើប-ភាវូបនីយកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសមាហរណកម្មប្រព័ន្ធមុខងារស្នូល កាន់តែប្រទាក់ក្រឡាជាងមុន រួមមាន ការចុះបញ្ជីពន្ធដារ (E-registration), ការដាក់លិខិតប្រកាសពន្ធ (E-filling), និងការបង់ប្រាក់ពន្ធ (E-payment), និងបន្តបង្កើនប្រសិទ្ធភាពសវនកម្មពន្ធ និងកាត់បន្ថយការធ្វើសវនកម្មពន្ធត្រួតគ្នា និងច្រើនលើកច្រើនសារ តាមរយៈការអនុវត្តសៀវភៅណែនាំស្តីពីបែបបទ និងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ (SOP on Auditing); និង
- បន្តពង្រឹងការគ្រប់គ្រងបំណុលពន្ធ សំដៅកាត់បន្ថយជាអតិបរមានូវបំណុលពន្ធបច្ចុប្បន្ន និងចៀសវាងការកើនឡើងបំណុលពន្ធអនាគត។

- **វិធានការដែលត្រូវអនុវត្តដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា រួមមាន៖**
  - បន្តតាមដាន និងរៀបចំវិធានការឆ្លើយតបទៅនឹងការដាក់ចេញនូវគោលនយោបាយពន្ធគយបដិការរបស់ប្រទេសជាដៃគូពាណិជ្ជកម្ម;
  - បន្តអនុវត្តវិធានការកែទម្រង់គន្លឹះ និងមុតស្រួចទាំង ១៤ នៃផ្នែកកិច្ចសម្រួលពាណិជ្ជកម្មក្រោមដែនសមត្ថកិច្ចគយ ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី ១៩;

- បង្កើនប្រសិទ្ធភាពការគ្រប់គ្រងការអនុវត្តអត្រាពន្ធអនុគ្រោះ ក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងការអនុវត្តគោលការណ៍លើកទឹកចិត្តពន្ធ និងអាករក្រោមក្របខ័ណ្ឌផ្សេងៗ, ពិសេសគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ);
- ពង្រឹងអនុលោមភាព និងរៀបចំយន្តការគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-commerce platform) និងជំរុញឱ្យមានការប្រើប្រាស់មុខងារទូទាត់ប្រាក់តាមមធ្យោបាយអេឡិចត្រូនិក (E-Payment) ឱ្យបានជាអតិបរមា;
- កែលម្អគោលនយោបាយពន្ធ និងអាករ សម្រាប់វិស័យអាទិភាព និងពង្រឹងការអនុវត្តគោលការណ៍លើកទឹកចិត្តពន្ធ និងអាករស្របតាមច្បាប់ និងបទប្បញ្ញត្តិថ្មីៗ;
- ពង្រីកវិសាលភាពការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម បន្តធ្វើសាមញ្ញកម្មដោយប្រើប្រាស់ឯកសារទម្រង់អេឡិចត្រូនិក និងកាត់បន្ថយឯកសារជាក្រដាស និងប្រើប្រាស់បញ្ញាសិប្បនិម្មិតក្នុងប្រតិបត្តិការគយ;
- បន្តពង្រឹងយន្តការធុរជនល្អបំផុត (Best Trader Mechanism) កែលម្អប្រព្រឹត្តកម្មលើកទឹកចិត្ត និងពង្រីកបន្ថែមការយល់ដឹងជាសាធារណៈអំពីអត្ថប្រយោជន៍នៃយន្តការ ព្រមទាំងបន្តជំរុញការអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត (Authorized Economic Operator Programme - AEO);
- ពង្រីកវិសាលភាពនៃប្រតិបត្តិការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ និងយកចិត្តទុកដាក់ប្រយុទ្ធប្រឆាំងទំនិញល្មើសកម្មសិទ្ធិបញ្ញា;
- លើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ម៉ាស៊ីនស្កេន ដោយត្រូវសិក្សា និងពិនិត្យលទ្ធភាពបំពាក់ម៉ាស៊ីនស្កេន នៅមាត់ច្រកសំខាន់ៗបន្ថែមទៀតដោយប្រើប្រាស់ថវិការដ្ឋ ដើម្បីគាំទ្រការពង្រឹងអនុលោមភាពដោយរក្សាបាននូវកិច្ចសម្រួលពាណិជ្ជកម្ម;
- ជំរុញការអនុវត្តពេញលេញនីតិវិធីបំពេញបែបបទគយមុនពេលទំនិញមកដល់ តាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីបង្កើនប្រសិទ្ធភាពនៃការងារគ្រប់គ្រងហានិភ័យគយ កាត់បន្ថយពេលឆ្លងកាត់ព្រំដែន និងចំណាយប្រតិបត្តិការផ្សេងៗ; និង
- បន្តពង្រឹងយន្តការភាពជាដៃគូជាមួយវិស័យឯកជន ក្នុងការពិគ្រោះយោបល់ និងដោះស្រាយបញ្ហានានា។

• **វិធានការផ្នែកចំណូលមិនមែនសារពើពន្ធ៖** ដើម្បីបន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រមូលឱ្យចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ ពីគ្រប់ប្រភពឱ្យដល់សក្តានុពល ដែលមាន, **គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់** ត្រូវអនុវត្តវិធានការ ដូចខាងក្រោម៖
  - ជំរុញការបញ្ចូលរាល់ប្រតិបត្តិការចំណូលមិនមែនសារពើពន្ធ នៅថ្នាក់រដ្ឋបាលកណ្តាលនៃក្រសួង ស្ថាប័ន និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងប្រព័ន្ធ NRMIS និងការធ្វើសន្ទានកម្មទិន្នន័យជាមួយប្រព័ន្ធ FMIS ប្រព័ន្ធ SARMIS និងប្រព័ន្ធសំខាន់ៗដទៃទៀត;
  - ពន្លឿនក្រសួង ស្ថាប័នក្នុងការបំពេញឱ្យបានប្រតិបត្តិការជាប្រក្រតី តាមការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន លើរាល់ប្រតិបត្តិការទាក់ទងនឹងការប្រមូលចំណូលទ្រព្យសម្បត្តិរដ្ឋ;

- រៀបចំផែនការសកម្មភាពជាក់លាក់តាមក្រសួងស្ថាប័ន ដែលទទួលបន្ទុកការប្រមូលចំណូលមិនមែនសារពើពន្ធ សំដៅជំរុញការកៀរគរនិងប្រមូលចំណូលមិនមែនសារពើពន្ធ, ជាពិសេសលើមុខចំណូលធំៗ សំខាន់ៗ, ឱ្យអស់សក្តានុពល និងបង់ចូលថវិការដ្ឋ ស្របតាមយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា;
- បន្តជំរុញការប្រើប្រាស់ e-Payment ឱ្យបានពេញលេញ ប្រកបដោយសុខដុមនីយកម្ម និងមានភាពងាយស្រួលក្នុងការទូទាត់;
- ពិនិត្យ និងជំរុញក្រុមហ៊ុនដែលទទួលបានសិទ្ធិពីរដ្ឋសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច និងក្រុមហ៊ុនធ្វើការសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មធនធានរ៉ែ, ឧស្ម័ន និងប្រេងកាតជាដើម ឱ្យបន្តដំណើរការអនុវត្តតាមកិច្ចសន្យា ឬចាត់វិធានការសមស្របតាមការចាំបាច់ចំពោះករណីមិនមានអនុលោមភាព;
- បន្តជំរុញការបង់ និងការកត់ត្រាចំណូលពីសហគ្រាសសាធារណៈ;
- បន្តពង្រឹងយន្តការប្រមូលចំណូលពីឥណទានកាបូនឱ្យមានប្រសិទ្ធភាព ស្របតាមតម្លៃសេដ្ឋកិច្ច;
- បន្តពង្រឹងប្រសិទ្ធភាពនៃការធ្វើសវនកម្ម ដើម្បីជំរុញការបំពេញចំណូលកាតព្វកិច្ចពីល្បែងកាស៊ីណូប្រចាំខែឱ្យបានត្រឹមត្រូវ និងតាមដានប្រតិបត្តិការកាស៊ីណូដែលបង់ចំណូលកាតព្វកិច្ចពីល្បែងមិនសមាមាត្រទៅនឹងទំហំអាជីវកម្ម ព្រមទាំងបន្តតឹងទារបំណុលដែលនៅសល់; និង
- បន្តពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូលកាតព្វកិច្ចពីសកម្មភាពល្បែងគ្រប់ប្រភេទដែលកំពុងដំណើរការស្របច្បាប់ ឱ្យអស់លទ្ធភាព។

### ៣.១.២-ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨

១៤-ក្របខ័ណ្ឌចំណាយសរុបថវិការដ្ឋ៖ តាមក្របខ័ណ្ឌតុល្យភាពរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ ខាងលើ, ចំណាយសរុបថវិការដ្ឋឆ្នាំ ២០២៦ ត្រូវបានគ្រោងក្នុងទំហំ **១៦,៨៣% នៃ ផ.ស.ស.** គឺថយប្រមាណ **១,៧%** ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥។ សម្រាប់ឆ្នាំ ២០២៧-២០២៨, កញ្ចប់ចំណាយសរុប នឹងគ្រោងឱ្យមានកំណើនសមគួរឡើងវិញ ក្នុងអត្រាជាមធ្យមប្រមាណ **៧,៨% ក្នុងមួយឆ្នាំ** ដែលនឹងស្ថិតក្នុងរង្វង់ **១៦,៧៤% នៃ ផ.ស.ស.** ត្រឹមឆ្នាំ ២០២៨។

- **ចំណាយចរន្តថវិការដ្ឋ** ត្រូវបានគ្រោងក្នុងទំហំ ១២,០៥% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២៦ ដែលមានកំណើនប្រមាណ ២,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥។ សម្រាប់ឆ្នាំ ២០២៧-២០២៨, ចំណាយចរន្តថវិការដ្ឋ ត្រូវបានគ្រោងឱ្យមានកំណើន ក្នុងអត្រាជាមធ្យមប្រមាណ ៥,៥% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ១១,៤៧% នៃ ផ.ស.ស. ត្រឹមឆ្នាំ ២០២៨។ **ចំណាយបន្ទុកបុគ្គលិក ក្នុងឆ្នាំ ២០២៦** ត្រូវបានគ្រោងឱ្យមានកំណើនក្នុងអត្រា ២,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥ សម្រាប់ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ និងការត្រៀមថវិកាសម្រាប់ចំណាយលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម ក្នុងរដ្ឋបាលសាធារណៈ ដើម្បីបង្កើនផលិតភាពការងារ និងពង្រឹងការផ្តល់សេវាសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព។ **សម្រាប់ឆ្នាំ ២០២៧-២០២៨**, ចំណាយបន្ទុកបុគ្គលិកត្រូវបានគ្រោងកើនជាមធ្យមក្នុងអត្រា ៤,២%។ ចំពោះ, **ចំណាយមិនមែនបន្ទុកបុគ្គលិក** ក្នុងឆ្នាំ ២០២៦ ត្រូវបានគ្រោងឱ្យមានកំណើនក្នុងអត្រា ២,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥ ស្របតាមស្មារតី

នៃការពង្រឹងប្រសិទ្ធភាពវិភាជថវិកា តាមរយៈការខិតខំតម្រង់ការវិភាជថវិកាឱ្យបានត្រឹមត្រូវ និងចំគោលដៅជាពិសេស សម្រាប់ឆ្លើយតបទៅនឹងកំណើននៃតម្រូវការចំណាយក្នុងការអនុវត្តគោលនយោបាយគាំពារសង្គម, ការត្រៀមលក្ខណៈក្នុងការអន្តរាគមន៍ក្សាលំនឹងសង្គម-សេដ្ឋកិច្ច និងចំណាយកាតព្វកិច្ច ក៏ដូចជាចំណាយចាំបាច់មិនអាចពន្យារពេលបាន។ ទន្ទឹមនេះ, ខិតខំធ្វើវិចារណកម្មចំណាយដោយត្បិតត្បៀតលើមុខសញ្ញាចំណាយមិនចាំបាច់ និងមិនសូវចាំបាច់ ដើម្បីរក្សាឱ្យបាននូវនិរន្តរភាពប្រតិបត្តិការរបស់ក្រសួង ស្ថាប័ន, បន្តជំរុញកម្មវិធីកែទម្រង់ជាអាទិភាព ក៏ដូចជាកម្មវិធីកែទម្រង់គន្លឹះនានា។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលក៏បានត្រៀមកញ្ចប់ថវិកាក្នុងកញ្ចប់ចំណាយត្រៀមបម្រុងមានមុខសញ្ញាសម្រាប់អនុវត្តនូវកម្មវិធីអន្តរាគមន៍ ដើម្បីរក្សាលំនឹងជីវភាពប្រជាជន និងលើកកម្ពស់សមធម៌សង្គមផងដែរ។ ដោយឡែក សម្រាប់ឆ្នាំ ២០២៧-២០២៨ ត្រូវបានគ្រោងឱ្យមានកំណើនជាមធ្យមក្នុងអត្រា ៦,៥%។

- **ចំណាយមូលធនថវិការដ្ឋ ត្រូវបានគ្រោងក្នុងទំហំ ៤,៧៨% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២៦ ដែលមានកំណើនអវិជ្ជមានក្នុងអត្រា -១០,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៥។** កំណើនអវិជ្ជមាននេះ បណ្តាលមកពីការថមថយនូវមូលនិធិទ្រទ្រង់ថវិកា ដែលជាប្រភពហិរញ្ញប្បទានក្រៅប្រទេស និងការបាត់បង់លក្ខខណ្ឌអនុគ្រោះពីប្រភពហិរញ្ញប្បទានប្រពៃណីដែលមានទម្រង់ជាហិរញ្ញប្បទានឥតសំណង និងឥណទានមានកម្រិតសម្បទានខ្ពស់ បន្ទាប់ពីការចាកចេញពីចំណាត់ថ្នាក់ប្រទេសមានចំណូលទាប។ យ៉ាងណាមិញ, ចំណាយមូលធនក្នុងឆ្នាំ ២០២៦ នៅតែបន្តផ្តល់ការគិតគូរដល់គម្រោងវិនិយោគសាធារណៈអាទិភាព ស្របតាមគោលដៅអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល និងតាមលទ្ធភាពដែលអាចទ្រទ្រង់បាន **ខណៈចំណាយវិនិយោគសាធារណៈ ដោយប្រភពហិរញ្ញប្បទានក្នុងប្រទេស ត្រូវបានរក្សាក្នុងកម្រិតស្មើច្បាប់ថវិកាឆ្នាំ ២០២៥។** សម្រាប់ឆ្នាំ ២០២៧-២០២៨ ចំណាយមូលធន ត្រូវបានគ្រោងឱ្យមានកំណើនឡើងវិញ ក្នុងអត្រាជាមធ្យមប្រមាណ ១៣,៧% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ៥,២៧% នៃ ផ.ស.ស. នៅឆ្នាំ ២០២៨។ កំណើននេះ បានគិតគូរពីតម្រូវការចំណាយចាំបាច់សម្រាប់ការអភិវឌ្ឍ និងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាជន, ការរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ច, ការលើកកម្ពស់ភាពប្រកួតប្រជែង និងការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ច ពោលគឺ រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពខ្ពស់ទៅលើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ជាពិសេស តាមរយៈការបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដែលមានគុណភាពខ្ពស់ និងការបង្កើនបរិមាណ និងគុណភាពនៃការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងបៃតង ដើម្បីកសាងមូលដ្ឋានគ្រឹះសម្រាប់ការធ្វើបរិវត្តកម្មឌីជីថល និងការបន្តជួសជុល, ស្តារ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា។

ទន្ទឹមនេះ, ក្របខ័ណ្ឌចំណាយតាមវិស័យរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ ត្រូវបានគិតបញ្ចូលទាំងចំណាយចរន្ត និងចំណាយមូលធន ទាំងលទ្ធភាពហិរញ្ញប្បទានដោយថវិកាជាតិ និងលទ្ធភាពហិរញ្ញប្បទានក្រៅប្រទេស ទាំងទ្វេភាគី និងពហុភាគី ហើយត្រូវបានកំណត់ដូចតទៅ៖

- **វិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងប្រមាណ ១,៥៣%, ១,៥៩%, និង ១,៥៥% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៦, ២០២៧ និង ២០២៨ រៀងគ្នា សំដៅបន្តគាំទ្រការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការងារការទូតសេដ្ឋកិច្ច បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ការងារទាក់ទាញនិងការគ្រប់គ្រង វិនិយោគឯកជន និងការពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍ ការធ្វើទំនើបកម្ម និងប្រព័ន្ធស្វ័យប្រវត្តិកម្មរដ្ឋបាលសារពើពន្ធ ការធ្វើទំនើបកម្ម

ការគ្រប់គ្រងចំណាយសាធារណៈ និងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ការកសាង និងការអភិវឌ្ឍសេដ្ឋកិច្ចធុរកិច្ចនិងសង្គមឌីជីថល ព្រមទាំងការបន្តត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត «យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»។

- **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងប្រមាណ ២,៦១%, ២,៥១%, និង ២,៤២% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៦, ២០២៧ និង ២០២៨ រៀងគ្នា សំដៅបន្តគាំទ្រដល់ការអនុវត្តកិច្ចការពារអធិបតេយ្យជាតិ, ការអនុវត្តកិច្ចការសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ, ការពង្រឹងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព», ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងនិងត្រួតពិនិត្យព្រំដែន, ការអភិវឌ្ឍចំណេះដឹង និងជំនាញវិជ្ជាជីវៈជូនកងកម្លាំងនគរបាលជាតិ, ការយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់-អាវុធ និងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌។
- **វិស័យសង្គមកិច្ច** ត្រូវបានគ្រោងប្រមាណ ៤,៩៥%, ៤,៩៦%, និង ៤,៨៩% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៦, ២០២៧ និង ២០២៨ រៀងគ្នា **ពោលគឺនៅតែចាត់ទុកជាវិស័យអាទិភាពទី ១** ក្នុងនោះសំដៅ បន្តរក្សាលំនឹងជីវភាពប្រជាជន ព្រមទាំងលើកកម្ពស់សមធម៌សង្គម, បន្តលើកកម្ពស់គុណភាពអប់រំ និងគាំទ្រដល់ការពង្រឹង និងពង្រីកការទទួលបានសេវាអប់រំ និងការអភិវឌ្ឍជំនាញ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ លើកកម្ពស់គុណភាពសេវាសុខាភិបាល និងការពង្រីកការទទួលបានសេវាថែទាំសុខភាពឆ្ពោះទៅរកការគ្របដណ្តប់សុខភាពសកលជំរុញការអនុវត្តកម្មវិធីគោលនយោបាយជាតិគាំពារសង្គម, ការបន្តផ្តល់របបសន្តិសុខសង្គម, ការលើកកម្ពស់យេនឌ័រ និងការបន្តគាំទ្រដល់គោលនយោបាយអាទិភាពផ្សេងទៀត ក្នុងផ្នែកសង្គមកិច្ចសាសនា វប្បធម៌ និងបរិស្ថាន។
- **វិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងប្រមាណ ៣,៧១%, ៣,៥៣%, និង ៣,៧៩% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៦, ២០២៧ និង ២០២៨ រៀងគ្នា ដោយផ្តោតសំខាន់លើការលើកកម្ពស់ផលិតភាពស្របតាមស្តង់ដា និងតម្រូវការទីផ្សារ បន្តដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ-សង្កាត់ទូទាំងប្រទេស ដើម្បីជំរុញការលើកកម្ពស់ផលិតភាពកសិកម្ម និងការរៀបចំឱ្យមានសមាគមកសិកម្មនៅតាមទីជនបទ គាំទ្រការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្នាំ ២០២៣-២០២៨ គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ឆ្នាំ ២០២០-២០៣០ ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ ២០២១-២០៣៥ គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជាឆ្នាំ ២០២២-២០៣៥ និង គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០២១-២០៣០។ល។

**១៥-ការកំណត់ពិតានចំណាយគោល៖** ផ្អែកលើក្របខ័ណ្ឌចំណាយតាមវិស័យរយៈពេលមធ្យមដែលបានកំណត់នេះ និងស្ថិតក្នុងបរិការណ៍នៃភាពមិនច្បាស់លាស់ពីផលប៉ះពាល់នៃបញ្ហាការអនុវត្តអត្រាពន្ធគយបដិការរបស់សហរដ្ឋអាម៉េរិក, ការកំណត់ពិតានចំណាយគោល សម្រាប់ក្រសួង ស្ថាប័ន ផ្នែកចំណាយមិនមែនបន្ទុកបុគ្គលិក

ជាទូទៅ ត្រូវបានផ្តល់ទាបជាងច្បាប់ថវិកាឆ្នាំ ២០២៥ ឬយ៉ាងច្រើនត្រូវបានរក្សាកញ្ចប់ស្មើនឹងច្បាប់ថវិកាឆ្នាំ ២០២៥ អាស្រ័យលើកត្តាជាក់ស្តែងនៃក្រសួង ស្ថាប័ន, ដោយផ្តល់អាទិភាពសម្រាប់ដោះស្រាយតម្រូវការចំណាយចាំបាច់មិនអាចខានបាន ឬមិនអាចពន្យារពេលបាន និងចំណាយតាមគោលការណ៍កំណត់ច្បាស់លាស់។ ជារួម, ក្រសួង ស្ថាប័នត្រូវបានដកចេញនូវសកម្មភាពដែលត្រូវបញ្ចប់ក្នុងឆ្នាំ ២០២៥ ឬកាត់បន្ថយមុខចំណាយមិនប្រចាំ ព្រមទាំងធ្វើវិចារណកម្មចំណាយមួយចំនួន ជាពិសេសចំណាយដែលអាចសន្សំសំចៃបាន ទាំងលើទិដ្ឋភាពប្រសិទ្ធភាពបច្ចេកទេស ទាំងលើទិដ្ឋភាពតម្លៃនៃលុយ។ សារៈសំខាន់នៃការកាត់បន្ថយនេះ គឺដើម្បីរក្សាលទ្ធភាពកម្រិតធនធានដែលមានក្នុងឆ្នាំ ២០២៥ ជាលំហថវិកា សម្រាប់ពិភាក្សានៅដំណាក់កាលចរចាថវិកា ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចមានលទ្ធភាពដោះស្រាយតម្រូវការចំណាយថ្មីៗ ដែលជាកិច្ចការអាទិភាពរបស់ក្រសួង ស្ថាប័ន និងរបស់រាជរដ្ឋាភិបាល ជាពិសេសសម្រាប់រាជរដ្ឋាភិបាលមានលទ្ធភាពត្រៀមលក្ខណៈឱ្យបាន-សមស្រប តាមដែលអាចធ្វើទៅបាន ក្នុងការធ្វើអន្តរាគមន៍ដោះស្រាយសំពាធចំណាយថ្មីៗ ដែលអាចកើតឡើងជាយថាហេតុ ពាក់ព័ន្ធនឹងការរក្សាលំនឹងជីវភាពប្រជាជន និងលំនឹងសេដ្ឋកិច្ច ហើយកាន់តែសំខាន់ទៅទៀតនោះគឺត្រៀមលក្ខណៈសម្រាប់សេណារីយ៉ូទាបជាយថាហេតុ ស្របតាមការវិភាគនៅក្នុងផ្នែកហានិភ័យហិរញ្ញវត្ថុសាធារណៈ នៃឯកសារក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨។

ស្របតាមវិធីសាស្ត្រ និងអភិក្រម ដូចបានជម្រាបជូននេះ, ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ បានកំណត់**ពិតានចំណាយគោលផ្នែកចំណាយចរន្ត** សម្រាប់គ្រប់ក្រសួង ស្ថាប័ន, ចំណែកឯ, **ពិតានចំណាយគោលផ្នែកចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ** ត្រូវបានកំណត់សម្រាប់ក្រសួង ស្ថាប័ន ចំនួន ១១ និង**ពិតានចំណាយគោលផ្នែកចំណាយមូលធនដោយហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ** ត្រូវបានកំណត់សម្រាប់ក្រសួង ស្ថាប័ន ចំនួន ១០ សម្រាប់ក្រសួង ស្ថាប័នធ្វើជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៦-២០២៨ និងសម្រាប់ការរៀបចំគម្រោងថវិកាឆ្នាំ ២០២៦។

ទន្ទឹមនេះ, ដើម្បីសម្រេចបាននូវគោលដៅរក្សាស្ថិរភាពសង្គម និងការងើបវិញនូវកំណើនសេដ្ឋកិច្ច, **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង គ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល** ចាំបាច់ត្រូវពង្រឹងប្រសិទ្ធភាពថវិកា, ទាំងផ្នែកវិភាជន៍ និងផ្នែកប្រតិបត្តិការ, ដោយឈរលើគោលការណ៍គោរពវិន័យថវិកាប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ និងឆ្លើយតបទៅនឹងទិសដៅគោលនយោបាយ និងកម្មវិធីកែទម្រង់នានា តាមរយៈការជំរុញការអនុវត្តវិធានការសំខាន់ៗ ប្រកបដោយការទទួលខុសត្រូវខ្ពស់ ដូចខាងក្រោម៖

- បន្តពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធលើកទឹកចិត្ត ចំពោះមន្ត្រីដែលមានគុណវុឌ្ឍិ ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ, សមិទ្ធកម្មការងារ, បង្កើនផលិតភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈក៏ដូចជាពិនិត្យលទ្ធភាពដំឡើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ ក្នុងគោលដៅរក្សាលំនឹងជីវភាពរស់នៅរបស់មន្ត្រីគ្រប់ថ្នាក់;
- កំណត់គោលការណ៍ក្នុងការជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មី, ទាំងមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់-អាវុធ, ដែលត្រូវសមាមាត្រនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ លើកលែងតែក្រសួងដែលទទួលបានគោលការណ៍ជាអាទិភាពដោយឡែក;

- បន្តអភិវឌ្ឍប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសគ្រប់កម្រិត ស្របតាមតម្រូវការទីផ្សារការងារ និងឌីជីថលភាវូបនីយកម្ម និងគាំទ្រដល់ផលិតកម្មដែលមានតម្លៃបន្ថែមខ្ពស់;
- បន្តពង្រឹងប្រព័ន្ធសុខាភិបាល ឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា និងបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីកសាងភាពធន់ និងលើកកម្ពស់សុខុមាលភាពសង្គម;
- បន្តតម្រង់ធនធានថវិកាលើវិស័យគន្លឹះ ដែលនឹងធានាឱ្យបានភាពធន់ បរិយាប័ន្ន និងចីរភាពនៃការ-អភិវឌ្ឍ តាមរយៈការផ្តល់អាទិភាពទៅលើការកែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់ជារចនាសម្ព័ន្ធ, ការអភិវឌ្ឍមូលធនមនុស្ស, និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តឌីជីថល ការជំរុញការធ្វើបរិវត្តកម្មឌីជីថល និងការអភិវឌ្ឍបៃតង;
- បន្តជំរុញពិពិធកម្មសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច តាមរយៈការអភិវឌ្ឍវិស័យដែលជាប្រភពថ្មីនៃកំណើន និងបន្តកៀរគរធនធានពីគ្រប់ប្រភពឱ្យអស់សក្តានុពល ដើម្បីលើកកម្ពស់ផលិតភាព និងប្រសិទ្ធភាពប្រកួតប្រជែង និងការអនុវត្តយន្តការហិរញ្ញប្បទាន និងផលិតផលហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់ការវិនិយោគដែលបង្កើនតម្លៃបន្ថែមខ្ពស់;
- កសាង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតាមបណ្តោយព្រំដែន ពិសេសផ្លូវក្រវាត់ព្រំដែន និងអភិវឌ្ឍតំបន់ភូមិភាគឦសាន ដែលមានសក្តានុពលសេដ្ឋកិច្ច ដោយផ្តោតលើវិស័យកសិ-ឧស្សាហកម្ម;
- ផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងលទ្ធភាពចំណូល ដែលមានប្រភពពីការប្រមូលចំណូលក្នុងប្រទេស ដោយខិតខំមិនប្រើប្រាក់សន្សំរបស់រាជរដ្ឋាភិបាល លើកលែងតែករណីចាំបាច់បំផុត ដើម្បីរក្សាតុល្យភាព និងចីរភាពថវិកា តាមរយៈការធ្វើអាទិភាវូបនីយកម្មចំណាយ និងពង្រឹងប្រសិទ្ធភាពថវិកា, ទាំងកម្រិតវិភាជន៍ និងប្រតិបត្តិការ;
- ពង្រឹងនីតិវិធីនៃការគ្រប់គ្រង, រៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈ និងការជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ជាពិសេសកែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ ដែលជាមូលដ្ឋានក្នុងការរៀបចំការវាយតម្លៃការជ្រើសរើសគម្រោង និងការប្រៀបធៀបតម្លៃគម្រោង ព្រមទាំងពិនិត្យ និងវាយតម្លៃហានិភ័យឱ្យបានហ្មត់ចត់ លើការអនុវត្តគម្រោងវិនិយោគសាធារណៈនីមួយៗ ដើម្បីអាចគ្រប់គ្រងលើហានិភ័យដែលអាចកើតមានឡើង និងកាត់បន្ថយចំណាយប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព;
- ពង្រឹងការតាមដាន និងវាយតម្លៃលើការអនុវត្តថវិកា ឱ្យកាន់តែហ្មត់ចត់លើភាពសមស្របនៃថ្លៃ, បរិមាណ និងគុណភាព ក្នុងគោលដៅបន្តលើកកម្ពស់បន្ថែមនូវប្រសិទ្ធភាពនៃការវិភាជថវិកា និងបង្កើនគុណភាពនៃការកំណត់សូចនាករគន្លឹះឱ្យបានសមស្រប;
- បន្តរក្សាចីរភាពបំណុលរយៈពេលមធ្យម និងវែង និងកម្រិតហានិភ័យបំណុលឱ្យនៅទាប តាមរយៈការកំណត់ពិតាននៃការខ្ចីប្រចាំឆ្នាំ និងការធានារបស់រដ្ឋ, ការកំណត់សូចនាករបំណុលគន្លឹះសំខាន់ៗ, ការកំណត់គោលដៅនៃការប្រើប្រាស់ហិរញ្ញប្បទាន និងការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យបានទូលំទូលាយ; និង

- បន្តពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ តាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព និងគណនេយ្យភាពនូវយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ ២០២៤-២០២៨ សំដៅធានាចីរភាពហិរញ្ញវត្ថុសាធារណៈ ដោយផ្តោតសំខាន់លើការវិនិយោគចំពោះវិស័យអាទិភាព ជាពិសេសវិស័យបង្កើនផលិតភាព និងតម្លៃបន្ថែម, ជំរុញការតភ្ជាប់, និងពង្រឹងភាពប្រកួតប្រជែង និង ពិពិធកម្មសេដ្ឋកិច្ច។

## ៤-គោលការណ៍ និងបច្ចេកទេសនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៦-២០២៨ និងការរៀបចំថវិកាឆ្នាំ ២០២៦

១៦-ផ្អែកលើក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ និងពិតានចំណាយគោល *ដូចមានភ្ជាប់ជូនក្នុងតារាង ១ និងតារាង ១.១,* គ្រប់ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៦-២០២៨ និងគម្រោងថវិកាឆ្នាំ ២០២៦ របស់ខ្លួន តាមគោលការណ៍ និងបច្ចេកទេស ដូចខាងក្រោម៖

### ៤.១-គោលការណ៍ និងបច្ចេកទេសនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៦-២០២៨

១៧-ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍ដ៏សំខាន់សម្រាប់៖ (១)-ផ្សារភ្ជាប់ថវិកាទៅនឹងគោល-នយោបាយរបស់ក្រសួង ស្ថាប័ន និងគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល, (២)-បង្កើនវិចារណកម្មអាទិភាពចំណាយរបស់ក្រសួង ស្ថាប័ន, (៣)-ធានានិរន្តរភាពនៃការអនុវត្តកម្មវិធីរបស់ក្រសួង ស្ថាប័ន, (៤)-ជាមូលដ្ឋានសម្រាប់ការពន្យល់ និងការបង្ហាញសេចក្តីសំអាងអំពីតម្រូវការថវិកាសម្រាប់ការងារអាទិភាព និង (៥)-ជាមូលដ្ឋានសម្រាប់ការរៀបចំ និងវិភាជថវិកាប្រចាំឆ្នាំឱ្យចំគោលដៅអាទិភាព។

១៨-ដូចនេះ, ក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិការួមមួយ ដែលត្រូវគ្របដណ្តប់ទាំងថវិការដ្ឋបាលកណ្តាល, ថវិកាមន្ទីរជំនាញរាជធានី-ខេត្ត និងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមឱវាទក្រសួង ស្ថាប័ននោះ ព្រមទាំងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដោយត្រូវធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន ព្រមទាំង រវាងថវិកាជាតិ និងថវិកាដោយហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ ដើម្បីធ្វើឱ្យផែនការយុទ្ធសាស្ត្រថវិកាមានគុណភាពកាន់តែល្អប្រសើរ ដែលជាមូលដ្ឋានដ៏សំខាន់ សម្រាប់ជួយលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជថវិកាប្រចាំឆ្នាំ។ ក្នុងន័យនេះ, *ក្រសួង ស្ថាប័ននីមួយៗ ត្រូវពង្រឹងក្រុមការងារថវិការបស់ខ្លួន ដែលមានសមាសភាពមកពីអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ឬ/និង ថវិកា/គណនេយ្យ ដែលហៅថា "**អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ**", អគ្គនាយកដ្ឋាន/នាយកដ្ឋានផែនការ, អង្គភាពថវិកា/អង្គភាពជំនាញ និងអង្គភាពគ្រប់គ្រងគម្រោង ឱ្យដំណើរការដោយសកម្ម និងប្រកបដោយការទទួលខុសត្រូវខ្ពស់* ដើម្បីធានាបាននូវផែនការយុទ្ធសាស្ត្រថវិកាប្រកបដោយគុណភាព និងភាពគ្រប់ជ្រុងជ្រោយ។

១៩-ផ្អែកលើកញ្ចប់ថវិកាដែលត្រូវបានកំណត់ក្នុងពិតានចំណាយគោល, ក្រសួង ស្ថាប័ននីមួយៗត្រូវរៀបចំផែនការថវិការយៈពេលមធ្យម (៣ ឆ្នាំ) ដោយត្រូវគោរពតាមពិតានចំណាយគោលដែលបានផ្តល់ជូន។ ជាមួយគ្នានេះ, ក្រសួង ស្ថាប័នត្រូវបានអនុញ្ញាតឱ្យគ្រោងនូវតម្រូវការធនធានថវិកាសម្រាប់អនុវត្តគោលនយោ-បាយថ្មីៗ ដែលជាយថាហេតុទើបទទួលបានការសម្រេចពីរាជរដ្ឋាភិបាលនៅក្នុងឆ្នាំអនុវត្តថវិកានេះ។ ដូចនេះ,

ក្រុមការងារថវិកាត្រូវខិតខំធានាឱ្យប្រាកដថា ទាំងធនធាន និងទាំងសកម្មភាពការងារអាទិភាពទាំងអស់របស់ក្រសួង ស្ថាប័នខ្លួន ត្រូវបានដាក់បញ្ចូល ឬឆ្លុះបញ្ចាំងក្នុងផែនការយុទ្ធសាស្ត្រថវិកា ដើម្បីធានាថាថវិកាត្រូវបានវិភាជចំអាទិភាព សកម្មភាព និងចំសេចក្ដីត្រូវការយ៉ាងពិតប្រាកដរបស់អង្គភាពអនុវត្តនីមួយៗ និងឆ្លើយតបបានជាអតិបរមាទៅនឹងគោលបំណងគោលនយោបាយ និងកម្មវិធីរបស់ក្រសួង ស្ថាប័ននីមួយៗ។ ជាមួយគ្នានេះ, គ្រប់ក្រសួង ស្ថាប័នត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន តាមទម្រង់ដូចមានភ្ជាប់ជូនក្នុង **ឧបសម្ព័ន្ធ ១**។

២០-ដើម្បីពង្រឹងការអនុវត្ត *អនុក្រឹត្យលេខ ២៤២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២១ ស្ដីពីការបង្កើនចំនួនអង្គភាពថវិកា និងការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនអង្គភាពថវិកា* ប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់, ក្រសួង ស្ថាប័ន ត្រូវកំណត់ **អង្គភាពថវិកា** និងអ្នកគ្រប់គ្រង ទៅតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធី (កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព) ឱ្យបានច្បាស់លាស់ ដើម្បីធានាឱ្យមានបន្ទាត់គណនេយ្យភាពដែលមានការទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រង និងអនុវត្តថវិកា។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងផ្ដល់ការបណ្ដុះបណ្ដាលសមត្ថភាពផ្នែកថវិកា និងនីតិវិធីហិរញ្ញវត្ថុ ក៏ដូចជាផ្ដល់ប្រឹក្សាផ្នែកបច្ចេកទេសពាក់ព័ន្ធតាមការចាំបាច់ ជូនដល់ទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ ដើម្បីមានសមត្ថភាពពេញលេញក្នុងការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម។

### ៤.១.១-ការគ្រោងចំណូលថវិកាសម្រាប់ឆ្នាំ ២០២៦-២០២៨

២១-ការគ្រោងចំណូល គឺត្រូវគ្រោងសម្រាប់រយៈពេល ៣ ឆ្នាំ ២០២៦-២០២៨ ដោយរួមទាំងចំណូល ដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្ទាល់ដោយក្រសួង ស្ថាប័ន និងចំណូលដែលបានមកពីហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ និងប្រភពផ្សេងៗទៀត។ ក្នុងការគ្រោងចំណូល ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវផ្ដោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម៖

- វាយតម្លៃការអនុវត្តការប្រមូលចំណូលក្នុងឆ្នាំកន្លងទៅ និងការប៉ាន់ស្មានការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកំពុងអនុវត្ត ដើម្បីគ្រោងចំណូលឆ្នាំ ២០២៦ និងព្យាករចំណូលឆ្នាំ ២០២៧-២០២៨
- ដាក់ចេញវិធានការដាក់ស្ដែងបន្ថែមទៀតតាមក្រសួង ស្ថាប័ននីមួយៗ ដើម្បីបង្កើនការប្រមូលចំណូល។

ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំផ្នែកនេះទៅតាម **តារាងគំរូដែលភ្ជាប់ជាមួយសារាចរនេះ**។ នៅក្នុងផ្នែកនេះ, ចំពោះក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដែលមិនមានប្រភពចំណូល គឺពុំតម្រូវឱ្យរៀបចំឡើយ។

ទន្ទឹមនេះ, ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានប្រភពចំណូល គឺត្រូវដាក់ចេញវិធានការដាក់ស្ដែងថ្មីៗបន្ថែមទៀត សម្រាប់ពង្រឹងការគ្រប់គ្រង និងខិតខំប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ឱ្យអស់សក្ដានុពល។ *ផ្ទុយទៅវិញ, ការគ្រោងចំណូលមិនអស់សក្ដានុពលដែលមាន គឺជាកម្មវត្ថុនៃការរឹតត្បិតផ្នែកចំណាយជំនួសវិញ នៅក្នុងកិច្ចប្រជុំចរចាកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់ក្រសួង ស្ថាប័ន ដែលមានការកិច្ចប្រមូលចំណូល។*

## ៤.១.២-ការគ្រោងចំណាយថវិកាសម្រាប់ឆ្នាំ ២០២៦-២០២៨

២២-ការគ្រោងតម្រូវការចំណាយ គឺជាការគណនាតម្រូវការសម្រាប់រយៈពេល ៣ ឆ្នាំ ២០២៦-២០២៨ ទៅតាមកម្មវិធីនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធាន ទាំងថវិកាជាតិ និងទាំងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ។ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី ៥ នេះ **តាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរនេះ។**

ក្នុងការគណនាអំពីតម្រូវការចំណាយ ដើម្បីអនុវត្តកម្មវិធីនីមួយៗ ត្រូវផ្តោតការយកចិត្តទុកដាក់លើមូលដ្ឋានសំខាន់ៗ ដូចខាងក្រោម៖

ទី១-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ ដែលរួមមានសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ដូចជា កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ អត្រាអតិផរណាប្រចាំឆ្នាំ និងគោលដៅសូចនាករចំណាយ ព្រមជាមួយនឹងគោលនយោបាយអាទិភាពដែលបានកំណត់ទាំងសម្រាប់ផ្នែកចំណាយចរន្ត និងផ្នែកចំណាយមូលធន

ទី២-ពិតានចំណាយគោល ដែលបានផ្តល់ជាកញ្ចប់ថវិកាសម្រាប់រយៈពេល ៣ ឆ្នាំ (២០២៦-២០២៨)

ទី៣-ការវាយតម្លៃការអនុវត្តចំណាយក្នុងឆ្នាំកន្លងមក និងការប៉ាន់ស្មានសមត្ថភាពអនុវត្តចំណាយក្នុងឆ្នាំ ២០២៥ ដែលបាននិងកំពុងអនុវត្ត,

ទី៤-ការកំណត់តម្រូវការថវិកាតាមឆ្នាំនីមួយៗ ដោយត្រូវគណនាតាមតម្រូវការជាក់ស្តែងនៃកម្មវិធីនីមួយៗ និងត្រូវស្របតាម**បញ្ជីស្តង់ដាថ្លៃទំនិញ និងសេវា ដែលបានកំណត់និងដាក់ឱ្យអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ដោយត្រូវគិតគូរឈរលើទិដ្ឋភាព ៣ ជាសំខាន់ រួមមាន ៖

- ផែនការសកម្មភាពការងារ ឬ គម្រោងមានស្រាប់ ដែលត្រូវបន្តអនុវត្ត,
- សកម្មភាពការងារដែលបញ្ចប់ត្រឹមមួយឆ្នាំ, និង
- សកម្មភាពការងារថ្មី តាមការសម្រេចរបស់រាជរដ្ឋាភិបាល។

ដូច្នេះ, ផ្អែកលើទិដ្ឋភាពនៃមូលដ្ឋានទាំង ៤ ខាងលើនេះ, គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទទាំងអស់ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវគ្រោងចំណាយសម្រាប់ឆ្នាំ ២០២៦-២០២៨ តាមគោលការណ៍បច្ចេកទេស ដូចខាងក្រោម៖

• **ចំណាយបន្ទុកបុគ្គលិក** (ជំពូក ៦៤)៖ សម្រាប់ឆ្នាំ ២០២៦, ក្រសួង ស្ថាប័ននីមួយៗត្រូវគ្រោងចំណាយបន្ទុកបុគ្គលិកទៅតាមគោលការណ៍ណែនាំលម្អិតសម្រាប់ការជ្រើសរើសចំនួនក្របខ័ណ្ឌថ្មី និងសម្រាប់ការផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិ និងបុណ្យភ្ជុំបិណ្ឌ ជូនដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន, ដែលមានចែងក្នុងចំណុច (ក) នៃផ្នែក **៤.២.២-អំពីការគ្រោងចំណាយបន្ទុកបុគ្គលិកឆ្នាំ ២០២៦**។ ដោយឡែក, សម្រាប់គម្រោងចំណាយបន្ទុកបុគ្គលិកឆ្នាំ ២០២៧ និងឆ្នាំ ២០២៨ ត្រូវគ្រោងក្នុង

កម្រិតក្របខ័ណ្ឌ និងកម្រិតបៀវត្សដែលបានគ្រោងសម្រាប់ឆ្នាំ ២០២៦ និងឆ្នាំ ២០២៧ រៀងៗគ្នា ហើយចំនួនក្របខ័ណ្ឌថ្មីយ៉ាងច្រើនត្រូវស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ និងផ្អែកលើការវិភាគមុខងារដែលទទួលបានការឯកភាពពីក្រសួងមុខងារសាធារណៈ។

• **ចំណាយក្រៅបន្ទុកបុគ្គលិក** (ជំពូក ៦០ ការទិញ, ជំពូក ៦១ សេវាកម្ម, ជំពូក ៦២ អត្ថប្រយោជន៍សង្គម, ជំពូក ៦៥ ឧបត្ថម្ភធន)៖ ត្រូវគ្រោងតាមគោលការណ៍ ដូចខាងក្រោម៖

- **ក្រសួង ស្ថាប័ននៅរដ្ឋបាលកណ្ដាល៖** ត្រូវគ្រោងថវិកាទៅតាមទំហំពិតានចំណាយគោលឆ្នាំ ២០២៦-២០២៨ ប៉ុន្តែ កញ្ចប់ថវិកាតាមពិតានចំណាយគោលនេះនឹងមិនទទួលបានជាស្វ័យប្រវត្តិនោះទេ គឺនៅជាកម្មវត្ថុនៃការពិនិត្យ និងពិភាក្សា ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការរៀបចំថវិកា និងប្រតិបត្តិការចំណាយ។ ក្នុងន័យនេះ, ក្រសួង ស្ថាប័នត្រូវកាត់ចេញនូវចំណាយលើមុខសញ្ញាចំណាយ ឬសកម្មភាពការងារណា ដែលត្រូវបញ្ចប់ក្នុងឆ្នាំ ២០២៥ ឬចំណាយមិនប្រចាំដែលមិនចាំបាច់និងលែងចាំបាច់ និងចំណាយដែលអាចពន្យារពេលបាន ដើម្បីរក្សាលំហថវិកាសម្រាប់សកម្មភាពការងារថ្មី ឬគម្រោងថ្មី ដែលទើបមានការសម្រេចរបស់រាជរដ្ឋាភិបាល ឬដែលក្រសួង ស្ថាប័នមានតម្រូវការអនុវត្តជាចាំបាច់ នៅក្នុងឆ្នាំអនុវត្តថវិកា។ ទន្ទឹមនេះ, រាល់ការគ្រោងចំណាយទាំងអស់ត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធ រួមមាន៖ ការសិក្សា, វិភាគ, វាយតម្លៃ និងការផ្ដល់អំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់ ទើបអាចដាក់ជាកម្មវត្ថុនៃការពិចារណា និងពិភាក្សាចរចា នៅពេលរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំបាន។

- **មន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ** (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)៖ ផ្អែកលើកញ្ចប់ពិតានចំណាយគោលរួមដែលផ្ដល់ជូនដល់មន្ទីរជំនាញរាជធានី ខេត្ត, ត្រូវគ្រោងយ៉ាងច្រើនបំផុតស្មើនឹងកម្រិតថវិកាអតិបរមានៃកញ្ចប់ពិតានចំណាយគោលនេះ។ ប៉ុន្តែ **ត្រូវកត់សម្គាល់ថា កញ្ចប់ថវិកាដែលគ្រោងផ្ដល់នេះ មិនទទួលបានជាស្វ័យប្រវត្តិទេ គឺតម្រូវឱ្យមន្ទីរជំនាញរាជធានី ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)** ត្រូវផ្ដល់ឯកសារពាក់ព័ន្ធដែលមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់ ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់  ពិសេសចំណាយមិនប្រចាំដើម្បីសន្សំសំចៃសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

- ដោយឡែក, សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យអប់រំ, ការគ្រោងកញ្ចប់ថវិកាត្រូវអនុវត្តតាមបទប្បញ្ញត្តិជាធរមាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

- **គ្រឹះស្ថានសាធារណៈរដ្ឋបាលនៃក្រសួង ស្ថាប័ននីមួយៗ** ត្រូវបានផ្ដល់ពិតានចំណាយគោលសម្រាប់ឧបត្ថម្ភធនរយៈពេល ៣ ឆ្នាំ (ឆ្នាំ ២០២៦-២០២៨) **ប៉ុន្តែកញ្ចប់ឧបត្ថម្ភធនដែលគ្រោងផ្ដល់នេះមិនទទួលបានជាស្វ័យប្រវត្តិទេ** គឺតម្រូវឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ ត្រូវផ្ដល់ការពន្យល់ និងអំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់នូវស្ថានភាពចំណូលផ្ទៃក្នុងរបស់គ្រឹះស្ថាន និងម្យ៉ាងទៀត, ក៏ត្រូវកាត់ចេញនូវទំហំចំណាយសម្រាប់សកម្មភាពដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃ ក៏ដូចជាសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់។

• **ចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាជាតិ** (ជំពូក ២១)៖ ត្រូវបានផ្តល់ពិតានចំណាយគោលសម្រាប់ក្រសួង ស្ថាប័នចំនួន ១១ រួមមាន៖ ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងមហាផ្ទៃ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងសុខាភិបាល, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្រសួងទាំង ១១ ត្រូវរៀបចំផែនការវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ជាបញ្ជីគម្រោងសម្រាប់ឆ្នាំ ២០២៦-២០២៨ ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគ ជាមួយនឹងគម្រោងចំណាយចរន្តនៅកម្រិតកម្មវិធី និងអនុកម្មវិធី និងដោយភ្ជាប់ជាមួយនូវបញ្ជីគម្រោងដែលបានរៀបចំ។ ទោះយ៉ាងនេះក្តី, ក្រសួងទាំង ១១ ខាងលើនេះ នឹងមិនទទួលបានកញ្ចប់ចំណាយវិនិយោគជាស្វ័យប្រវត្តិទេ, ការធ្វើអាទិភាវូបនីយកម្មគម្រោង និងការផ្តល់ថវិកា គឺជាកម្មវត្ថុនៃការពិនិត្យពិភាក្សាតាមយន្តការគណៈកម្មការ និងក្រុមការងារអន្តរក្រសួង។ ចំពោះ ក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដែលមានតម្រូវការចំណាយវិនិយោគ ក៏ត្រូវចាប់ផ្តើមសិក្សារៀបចំផែនការវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ឱ្យច្បាស់លាស់ និងរៀបចំលើកសំណើគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំធ្វើអាទិភាវូបនីយកម្មគម្រោងតាមការចាំបាច់ ហើយគោរពស្នើសុំប្រមុខរាជរដ្ឋាភិបាល ពិនិត្យសម្រេចតាមលទ្ធភាពថវិកា និងតាមវិធានការផ្ទេរចំណាយដែលបានកំណត់នៅផ្នែកខាងលើនៃសារាចរនេះ។

• **ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ**៖ ត្រូវបានផ្តល់ជាពិតានចំណាយគោលសម្រាប់ក្រសួង ស្ថាប័នចំនួន ១០ រួមមាន៖ ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងមហាផ្ទៃ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងសុខាភិបាល, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ចំពោះក្រសួង ស្ថាប័នដទៃទៀតដែលបាន និងកំពុងទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការ ឬគ្រោងនឹងទទួលបានហិរញ្ញប្បទាន ស្របតាមកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (២០២៦-២០២៨) ត្រូវគ្រោងឱ្យបានត្រឹមត្រូវទៅតាមកិច្ចព្រមព្រៀង ឬអនុស្សរណៈនៃការយោគយល់គ្នា ឬការសន្យាតាមរយៈយន្តការផ្សេងៗ។

## ៤.២-គោលការណ៍ និងបច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០២៦

២៣-ផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដូចបានកំណត់ខាងលើ ក្រសួង ស្ថាប័ននីមួយៗ ត្រូវគ្រោងចំណូល-ចំណាយឆ្នាំ ២០២៦ តាមគោលការណ៍ និងបច្ចេកទេស ដូចខាងក្រោម៖

### ៤.២.១-ការគ្រោងចំណូលថវិកាឆ្នាំ ២០២៦

២៤-ការគ្រោងគិតចំណូលថវិកាចរន្ត អាស្រ័យលើប្រភពធនធាននៃផលិតផល ឬផលទុន ដែលជាប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងលក្ខខណ្ឌនៃប្រភព

ធនធានដូចបានលើកឡើងខាងលើ, ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួន តាមគោលការណ៍ ដូចតទៅ៖

- **ចំណូលសារពើពន្ធ** ត្រូវគិតគូរដោយផ្អែកលើមូលដ្ឋាន ដូចខាងក្រោម៖
    - លទ្ធផលដែលសម្រេចនៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ (ឆ្នាំ ២០២៥);
    - ចំណូលបន្ថែមដែលសង្ឃឹមថានឹងប្រមូលបាន ដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ គោលនយោបាយគយនិងរដ្ឋាករ ការធ្វើវិចារណកម្មសារពើពន្ធ និងការប្រមូលបំណុលពន្ធដែលត្រូវទារ;
    - ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ច និងអាជីវកម្មនៅពេលខាងមុខ;
    - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើអត្រានិងមូលដ្ឋានប្រមូលពន្ធ។
- **ចំណូលមិនមែនសារពើពន្ធ** ត្រូវគិតគូរទៅតាមគោលការណ៍ ដូចខាងក្រោម៖
    - **ផ្នែកចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ៖** ត្រូវបន្តសិក្សាលទ្ធភាពកែសម្រួលកម្រៃសេវា និងអត្រាសួយសារពាក់ព័ន្ធនឹងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងការកែសម្រួលកិច្ចសន្យាសម្បទានគ្រប់ប្រភេទ និងកិច្ចសន្យាជួលសេវាកម្មគ្រប់ប្រភេទ, ត្រូវពិនិត្យ និងជំរុញក្រុមហ៊ុនដែលទទួលបានសិទ្ធិពីរដ្ឋសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច និងក្រុមហ៊ុនដែលធ្វើការសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មធនធានរ៉ែ ឧស្ម័ន និងប្រេងកាត ជាដើម ឱ្យបន្តដំណើរការអនុវត្តតាមកិច្ចសន្យា ឬចាត់វិធានការសមស្របចំពោះករណីមិនមានអនុលោមភាព ព្រមទាំងត្រូវបន្តកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការប្រមូលបំណុលដែលត្រូវទារ ជាដើម ។ល។
    - **ផ្នែកចំណូលមិនមែនសារពើពន្ធ៖** ត្រូវអនុវត្តម៉ឺងម៉ាត់តាមវិធានការផ្នែកចំណូលមិនមែនសាពើពន្ធដែលបានកំណត់នៅទំព័រទី <u>១១</u> នៃសារាចរនេះ។ ទន្ទឹមនេះ, ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវគិតគូរដាក់ចេញនូវវិធានការដាក់ស្តែងបន្ថែម ដើម្បីពង្រឹងការកៀរគរ៖
        - ចំណូលពីប្រភពដែលនៅមានសក្តានុពល មានដូចជា ចំណូលពីសម្បទានរ៉ែ, ចំណូលពីវិស័យប្រៃសណីយ៍និងទូរគមនាគមន៍, ផលទុនសកម្មភាពទេសចរណ៍, អាកាសយានដ្ឋានទូត និងផលទុនរបស់អាកាសចរស៊ីវិល ដែលត្រូវបានរំពឹងទុកថានឹងមានកំណើន,
        - ចំណូលដែលអាចមានកំណើន តាមរយៈការពង្រឹងអភិបាលកិច្ចស្ថាប័ន ដោយត្រូវរៀបចំដាក់ចេញនូវផែនការសកម្មភាពជាក់លាក់នៅតាមក្រសួង ស្ថាប័ន។

## ៤.២.២- ការគ្រោងចំណាយថវិកាឆ្នាំ ២០២៦

២៥-ថវិកាព័ត៌មានសមិទ្ធកម្ម ឬហៅខ្លីថា "ថវិកាសមិទ្ធកម្ម" ព្រមជាមួយនឹងការរៀបចំនូវកិច្ចព្រមព្រៀងសមិទ្ធកម្ម ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងចាប់ពីឆ្នាំ ២០២៣ ដើម្បីធានាការអនុវត្តជាមូលដ្ឋាននូវថវិកាព័ត៌មានសមិទ្ធកម្មនៅឆ្នាំ ២០២៦ ស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៣។ ដូចនេះ, ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់

មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវជំរុញលើកកម្ពស់ប្រសិទ្ធភាពនៃការ-វិភាជ ដោយត្រូវផ្តោតការយកចិត្តទុកដាក់ឱ្យកាន់តែខ្លាំងលើការកំណត់លទ្ធផល ឬធាតុចេញ (Output) ដែលនឹងត្រូវសម្រេចបានចំពោះកម្មវត្ថុចំណាយ ឬមុខសញ្ញាចំណាយ ឬគម្រោងចំណាយនីមួយៗ។ ក្នុងន័យនេះ, ក្រសួង ស្ថាប័នត្រូវពង្រឹងបន្ថែមនូវប្រសិទ្ធភាពនៃការគ្រោងថវិកាទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ការពិភាក្សាចរចាថវិកា ក៏ដូចជាសម្រាប់ការធ្វើវិមជ្ឈការសិទ្ធិអំណាចនៃការអនុវត្តចំណាយផងដែរ។ លើសពីនេះ, ក្រសួង ស្ថាប័ន ក៏ត្រូវកែលម្អរចនាសម្ព័ន្ធកម្មវិធី និងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនឱ្យកាន់តែស៊ីសង្វាក់គ្នា និងមានលក្ខណៈសមាហរណកម្មក្នុងកម្រិតវិស័យ, ម្យ៉ាង, ដើម្បីសម្រេចបានលទ្ធផលល្អ និងមានការទទួលខុសត្រូវកាន់តែច្បាស់លាស់ និងម្យ៉ាងទៀត, ដើម្បីសម្រួលដល់ការអនុវត្តថវិកាឱ្យកាន់តែរលូនល្អផងដែរ។ ជាមួយគ្នានេះ, *ក្រសួង ស្ថាប័ន ត្រូវយកចិត្តទុកដាក់ក្នុងការកំណត់គោលបំណង និងកត្តាកំណត់ជោគជ័យនៃកម្មវិធី និងអនុកម្មវិធី ឱ្យបានល្អ ដើម្បីធានាបាននូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយ ពិសេសត្រូវកំណត់សូចនាករគន្លឹះ និងគោលដៅសូចនាករឱ្យបានត្រឹមត្រូវ និងច្បាស់លាស់។*

**២៦-ការរៀបចំផែនការសមិទ្ធកម្ម៖** ក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំផែនការសមិទ្ធកម្ម (សូចនាករគន្លឹះ និងគោលដៅសូចនាករ) ប្រចាំឆ្នាំ ដូចមានភ្ជាប់ជូនក្នុង **តារាង ក** ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបូកសរុបជាឯកសារឧបសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦ ព្រមទាំងសម្រាប់ជាកម្មវត្ថុនៃការតាមដានវឌ្ឍនភាពនៃការអនុវត្តថវិកាសមិទ្ធកម្ម។ ក្នុងន័យនេះ, ក្រសួង ស្ថាប័នត្រូវផ្ញើ **ផែនការសមិទ្ធកម្មដោយភ្ជាប់មកជាមួយនឹងគម្រោងថវិកាឆ្នាំ ២០២៦ របស់ខ្លួន** មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (*អគ្គនាយកដ្ឋានថវិកា*) តាមកាលបរិច្ឆេទកំណត់ក្នុងសារាចរនេះ។

**២៧-កិច្ចព្រមព្រៀងសមិទ្ធកម្ម** ត្រូវបានកំណត់ជា ៣ កម្រិត៖ *(ទី១)-រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នសាមី, (ទី២)-រវាងរដ្ឋមន្ត្រីក្រសួង ស្ថាប័ន ជាមួយនឹងអ្នកគ្រប់គ្រងកម្មវិធីនៅតាមក្រសួង ស្ថាប័នសាមី, និង (ទី៣)-រវាងអ្នកគ្រប់គ្រងកម្មវិធីជាមួយនឹងប្រធានអង្គភាពថវិកា* ដូចមានភ្ជាប់ជូននូវគំរូកិច្ចព្រមព្រៀង *សមិទ្ធកម្មទាំង ៣ កម្រិតនេះ។ ដូចនេះ, ក្រសួង ស្ថាប័ន ត្រូវរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្ម តាមកញ្ចប់ថវិកាដែលទទួលបានឯកភាព និងវិភាជជូន តាមស្មារតីនៃការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង។*

**២៨-គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ** (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវរៀបចំគម្រោងចំណាយដែលឆ្លុះបញ្ចាំងលម្អិតតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា (ជំពូក គណនី និងអនុគណនី) ព្រមទាំងត្រូវវិភាគឱ្យបានច្បាស់លាស់អំពីតម្រូវការចំណាយតាមចង្កោមសកម្មភាព អនុកម្មវិធី និងកម្មវិធី និងត្រូវភ្ជាប់មកជាមួយនូវឯកសារសម្រាប់គាំទ្រ រួមទាំងឯកសារអង្កេត ឬវិភាគតាមការចាំបាច់ ព្រមទាំងពន្យល់បញ្ជាក់អំពីភាពចាំបាច់នៃតម្រូវការចំណាយលើសកម្មភាពការងារនីមួយៗឱ្យបានគ្រប់ជ្រុងជ្រោយ ហើយឯកសារទាំងនេះ ក៏ជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យ ពិភាក្សា និងចរចាថវិកាផងដែរ។ លើសពីនេះ, ការគណនាតម្រូវការចំណាយត្រូវផ្អែកលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជា ចំណាយបន្ទុកបុគ្គលិក និងចំណាយមិនមែនបន្ទុកបុគ្គលិក ដែលត្រូវប៉ាន់ស្មានតម្លៃធាតុចូលដែលត្រូវការជាក់ស្តែង ដោយធៀបនឹងតម្រូវការប្រើប្រាស់

ក្នុងឆ្នាំ ២០២៤ និងការប៉ាន់ស្មាននៃការអនុវត្តក្នុងឆ្នាំ ២០២៥ និងដោយផ្អែកលើថ្លៃឯកតា **ស្របតាមបញ្ជីស្តង់ដារថ្លៃទំនិញនិងសេវាដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ឬថ្លៃទីផ្សារ (ក្នុងករណីមិនមានកំណត់ក្នុងបញ្ជីស្តង់ដារថ្លៃទំនិញនិងសេវា) ក៏ដូចជា តាមគោលរបបកំណត់ ជាដើម។ ដូចនេះ, ស្របតាមផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំ និងដាក់ឱ្យអនុវត្ត **ស្តង់ដារថ្លៃទំនិញ និងសេវាសម្រាប់កិច្ចលទ្ធកម្មសាធារណៈ** ដើម្បីធានាបាននូវតម្លាភាព, គណនេយ្យភាព និងប្រសិទ្ធភាពនៃចំណាយសាធារណៈ ដោយពង្រីកវិសាលភាពនៃការអនុវត្តសម្រាប់ការរៀបចំថវិកាឆ្នាំ ២០២៦ ទៅដល់ ១០ ក្រសួង ស្ថាប័ន រួមមាន៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងយុត្តិធម៌, ក្រសួងរ៉ែនិងថាមពល, ក្រសួងធម្មការនិងសាសនា, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងមហាផ្ទៃ, ក្រសួងពាណិជ្ជកម្ម, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងកិច្ចការនារី និង អង្គភាពប្រឆាំងអំពើពុករលួយ។

២៩-ឈរលើមូលដ្ឋានតម្រូវការចំណាយ ដែលបានប៉ាន់ស្មានក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៦-២០២៨, **សម្រាប់ឆ្នាំ ២០២៦** ក្នុងកម្រិតនៃកញ្ចប់ពិតានចំណាយគោលដែលបានផ្តល់ជូន **ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ)** ត្រូវគ្រោងចំណាយរបស់ខ្លួនទៅតាមគោលការណ៍ និងបណ្តាវិធានការ ដូចខាងក្រោម៖

**ក-ចំណាយបន្ទុកបុគ្គលិក(ជំពូក ៦៤)៖** នាយកដ្ឋានបុគ្គលិក/អង្គភាពគ្រប់គ្រងធនធានមនុស្ស ដែលជាសេនាធិការរបស់ក្រសួង ស្ថាប័ននីមួយៗ ត្រូវសម្របសម្រួល និងគ្រោងចំណាយបន្ទុកបុគ្គលិកឱ្យបានសុក្រឹតតាមគោលការណ៍ ព្រមជាមួយនឹងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ពោលគឺត្រូវចៀសវាងការគ្រោងបៀវត្ស ឬបន្ទុកពាក់ព័ន្ធនឹងបុគ្គលិកនេះទុកចោល។ ក្នុងន័យនេះ, ការគ្រោងចំណាយបន្ទុកបុគ្គលិកសម្រាប់ឆ្នាំ ២០២៦ ត្រូវអនុវត្តនូវគោលការណ៍លម្អិត ដូចខាងក្រោម៖

- **ចំនួនក្របខ័ណ្ឌថ្មី** ត្រូវគ្រោងយ៉ាងច្រើនស្មើនឹងចំនួនមន្ត្រីចូលនិវត្តន៍ក្នុងឆ្នាំ ២០២៥ និងដោយផ្អែកលើការវិភាគមុខងារដែលទទួលបានការឯកភាពពីក្រសួងមុខងារសាធារណៈ។ ទន្ទឹមនេះ, ចំពោះមន្ត្រីដែលព្យួរការងារ និងមន្ត្រីដែលចូលបម្រើការងារវិញ ត្រូវគ្រប់គ្រង និងគ្រោងថវិកាឱ្យបានត្រឹមត្រូវ និងហ្មត់ចត់ផងដែរ។
- **បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារ៖** គ្រប់ក្រសួង ស្ថាប័ន ត្រូវគ្រោងដោយផ្អែកលើមូលដ្ឋានឆ្នាំ ២០២៥។ ទន្ទឹមនេះ, ក្រសួង ស្ថាប័ន អាចគ្រោងថវិកាសម្រាប់ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ ស្របតាមបទបញ្ញត្តិជាធរមាន។
- គ្រោងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិចំនួន **៥ ម៉ឺនរៀល** ក្នុងម្នាក់ និងក្នុងឱកាសបុណ្យភ្ជុំបិណ្ឌចំនួន **៥ ម៉ឺនរៀល ក្នុងម្នាក់** ជូនដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន និង

- គ្រោងចំនួនមន្ត្រីជាប់កិច្ចសន្យាមិនឱ្យលើសពីចំនួន ដែលក្រសួងមុខងារសាធារណៈផ្តល់ជូនក្នុងឆ្នាំ ២០២៥ និងមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំពោះប្រាក់ឧបត្ថមមន្ត្រីជាប់កិច្ចសន្យា ត្រូវគ្រោងតាមអត្រាដែលត្រូវបានកំណត់ក្នុងឆ្នាំ ២០២៥។

ទន្ទឹមនេះ, សម្រាប់ការគ្រោងថវិកាឆ្នាំ ២០២៦, គ្រប់ក្រសួង ស្ថាប័ន (**ទាំងថ្នាក់កណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត) ត្រូវគ្រោងចំណាយបន្ទុកបុគ្គលិក ទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពនីមួយៗ** ស្របតាមគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម។ ក្នុងន័យនេះ, គ្រប់ក្រសួង ស្ថាប័ន ត្រូវពិនិត្យឱ្យហ្មត់ចត់លើការអនុវត្តជាក់ស្តែង នាឆ្នាំកន្លងទៅ និងឆ្នាំកំពុងអនុវត្ត ដើម្បីបង្កើនសុក្រឹត្យភាពដល់ការគ្រោងចំណាយបន្ទុកបុគ្គលិកទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពនីមួយៗ។

**ខ-ចំណាយក្រៅបន្ទុកបុគ្គលិក (ជំពូក ៦០ ការទិញ, ជំពូក ៦១ សេវាកម្ម, ជំពូក ៦២ អត្ថប្រយោជន៍សង្គម, ជំពូក ៦៥ ឧបត្ថម្ភធន)៖** *គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវកាត់ចេញនូវមុខសញ្ញាចំណាយដែលបានបញ្ចប់ ឬដែលមិនចាំបាច់ និងមិនសូវចាំបាច់ ដើម្បីសន្សំថវិកាសម្រាប់មុខសញ្ញាចំណាយថ្មី ឬសកម្មភាពថ្មីដែលចាំបាច់ ឬដែលបម្រើឱ្យសកម្មភាពថ្មីៗនៃកម្មវិធីកែទម្រង់គន្លឹះៗ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងទ្រទ្រង់កំណើនសេដ្ឋកិច្ច។* ដូចនេះ, ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវគ្រោង និងគណនាតម្រូវការចំណាយនៃជំពូកនីមួយៗ តាមគោលការណ៍ ដូចខាងក្រោម៖

- ***ចំណាយជាប្រចាំ*** គឺជាចំណាយដែលមានតម្រូវការជារៀងរាល់ឆ្នាំ រួមមាន៖ ចំណាយលើសម្ភារផ្គត់ផ្គង់ និងការថែទាំជាប្រចាំ (ដូចជា៖ សម្ភារ ក៏ដូចជាសេវាថែទាំតូចតាច សម្រាប់បម្រើទៅដល់ការថែទាំ និងជួសជុលអគារ, ប្រាសាទ, ផ្លូវថ្នល់, ស្ពាន, លូ, ប្រព័ន្ធធារាសាស្ត្រ, រថយន្ត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ), និង សម្ភារផ្គត់ផ្គង់រដ្ឋបាល (ដូចជា៖ សម្ភារការិយាល័យ, ការបោះពុម្ព, ការទិញឯកសារ, សម្ភារបរិក្ខារប្រើប្រាស់ជាប្រចាំ, ស្បៀងអាហារ និងឯកសណ្ឋាន សម្រាប់ក្រសួង ស្ថាប័នត្រូវការប្រើប្រាស់ជាប្រចាំ ព្រមទាំងចំណាយលើអគ្គិសនី ទឹក ប្រេងឥន្ធនៈ និងទូរស័ព្ទជាដើម)។ យ៉ាងណាមិញ, **ប្រភេទចំណាយនេះ ត្រូវកំណត់ឱ្យបានត្រឹមត្រូវ និងបង្កើតមូលដ្ឋានគណនាតម្រូវការឱ្យបានច្បាស់លាស់** ស្របតាមតម្រូវការជាក់ស្តែង ព្រមទាំងត្រូវ**វិភាជទៅតាមអង្គភាពថវិកា នាយកដ្ឋាន ឬអង្គភាពជំនាញដែលអនុវត្តផ្ទាល់**។ មុខចំណាយប្រភេទនេះ ក៏ត្រូវគ្រោងដោយឈរលើគោលការណ៍សន្សំសំចៃ និងភាពចាំបាច់ផងដែរ។
- ***ចំណាយមិនប្រចាំ*** គឺជាចំណាយដែលមិនកើតឡើងជារៀងរាល់ឆ្នាំ រួមមាន៖ ចំណាយលើការទិញឧបករណ៍, សម្ភារដឹកជញ្ជូន, សម្ភារបរិក្ខារបច្ចេកទេស, គ្រឿងសង្ហារិម និងឧបករណ៍សម្ភារប្រើប្រាស់ធំៗផ្សេងទៀត ក៏ដូចជាគម្រោង ឬសកម្មភាពការងារថ្មី ដែលត្រូវអនុវត្ត និងត្រូវបញ្ចប់វិញក្នុងពេល ១ ឆ្នាំ ព្រមទាំងចំណាយសម្រាប់ការងារជួសជុល, បោះពុម្ព, ការរៀបចំកិច្ចប្រជុំ និងសិក្ខាសាលា និងបេសកកម្មមួយចំនួន ដែលមិនមែនជាសកម្មភាពជាប្រចាំឆ្នាំ។ សម្រាប់ប្រភេទចំណាយនេះ គឺត្រូវគ្រោងដោយមានមូលដ្ឋានគណនាច្បាស់លាស់អំពីតម្រូវការ រយៈពេលអនុវត្ត និងប្រសិទ្ធភាពនៃការប្រើប្រាស់ សម្រាប់ទាំងរយៈពេលខ្លី និងរយៈពេលមធ្យម។

- ក្រសួង ស្ថាប័ននៅរដ្ឋបាលកណ្ដាលៈ ត្រូវគ្រោងថវិកាទៅតាមពិតានចំណាយគោលឆ្នាំ ២០២៦ ប៉ុន្តែ*កញ្ចប់ថវិកាតាមពិតានចំណាយគោលនេះ នឹងមិនទទួលបានជាស្វ័យប្រវត្តិនោះទេ*។ ដូចនេះ, រាល់ការគ្រោងចំណាយទាំងអស់ ត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធ រួមមានៈ ការសិក្សា, ការវិភាគ, ការវាយតម្លៃ និងការផ្ដល់អំណះអំណាងឱ្យបានត្រឹមត្រូវ និងច្បាស់លាស់។ ក្នុងន័យនេះ, គម្រោងចំណាយដែលមានឯកសារគាំទ្រគ្រប់គ្រាន់ទើបអាចអនុញ្ញាតឱ្យដាក់ជាកម្មវត្ថុនៃការពិភាក្សា ទាំងនៅក្នុងកិច្ចប្រជុំពិភាក្សាថវិកាកម្រិតបច្ចេកទេស និងកិច្ចប្រជុំពិភាក្សាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង ស្ថាប័ន។ នេះ គឺមានន័យថា ពិតានចំណាយគោល គឺនៅតែជាកម្មវត្ថុសម្រាប់ការពិភាក្សានៅពេលចរចាថវិកា ដើម្បីបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា ក៏ដូចជាដើម្បីសន្សំសំចៃថវិកាសម្រាប់បំពេញតម្រូវការចំណាយចាំបាច់ថ្មីៗ។

- **មន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ** (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)ៈ ផ្អែកលើ **កញ្ចប់ពិតានចំណាយគោលរួម** ដែលផ្ដល់ជូនដល់មន្ទីរជំនាញរាជធានី ខេត្ត, សម្រាប់ឆ្នាំ ២០២៦ មន្ទីរជំនាញរាជធានី ខេត្ត និងរដ្ឋបាលរាជធានី ខេត្តពាក់ព័ន្ធ ត្រូវគ្រោងថវិកាចំណាយយ៉ាងច្រើនបំផុតស្មើនឹងកម្រិតអតិបរមានៃកញ្ចប់ពិតានចំណាយគោល។ ក៏ប៉ុន្តែ ***កញ្ចប់ថវិកាតាមពិតានចំណាយគោលនេះ*** **នឹងមិនទទួលបានជាស្វ័យប្រវត្តិទេ** គឺតម្រូវឱ្យមន្ទីរជំនាញរាជធានី ខេត្ត និងរដ្ឋបាលរាជធានី ខេត្តពាក់ព័ន្ធ ត្រូវផ្ដល់ឯកសារពាក់ព័ន្ធដែលមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់ ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ ពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

- ដោយឡែក, សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យអប់រំ, ការគ្រោងកញ្ចប់ថវិកាត្រូវអនុវត្តតាមបទបញ្ញត្តិជាធរមាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច, ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

- **គ្រឹះស្ថានសាធារណៈរដ្ឋបាលនៃក្រសួង ស្ថាប័ន**នីមួយៗ ត្រូវបានផ្ដល់ពិតានចំណាយគោលសម្រាប់ឧបត្ថម្ភធន ប៉ុន្តែ**កញ្ចប់ឧបត្ថម្ភធនដែលគ្រោងផ្ដល់នេះមិនទទួលបានជាស្វ័យប្រវត្តិទេ** គឺតម្រូវឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ ត្រូវផ្ដល់ការពន្យល់ និងអំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់នូវស្ថានភាពចំណូលផ្ទៃក្នុងរបស់គ្រឹះស្ថាន និងម្យ៉ាងទៀត ក៏ត្រូវកាត់ចេញនូវទំហំចំណាយសម្រាប់សកម្មភាពដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំដើម្បីសន្សំសំចៃ ក៏ដូចជាសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីៗដែលចាំបាច់។

- ចំពោះការបន្តអនុវត្តសកម្មភាពការងារកំពុងដំណើរការ ត្រូវគ្រោងចំណាយនៃកម្មវិធីនីមួយៗ ដោយផ្អែកលើបរិមាណធាតុចូលដែលធ្លាប់ប្រើក្នុងឆ្នាំ ២០២៤ កន្លងមក និងការប៉ាន់ស្មានអនុវត្តនៅក្នុងឆ្នាំ ២០២៥ នេះ និងផ្អែកលើថ្លៃឯកតាជាក់ស្ដែង ហើយចៀសវាងការបង្កើនបរិមាណធាតុចូលលើសពីតម្រូវការដែលធ្លាប់មាន។ ទន្ទឹមនេះ, ត្រូវគ្រោងថវិកាប្រកបដោយលក្ខណៈត្បិតត្បៀត និងសន្សំសំចៃខ្ពស់ ជាពិសេសលើមុខសញ្ញាទិញឧបករណ៍ សម្ភារបរិក្ខារទំនើប គ្រឿងសង្ហារិមប្រណិត ការបោះពុម្ពប្រណិត សម្ភារការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវអធឹកអធម បេសកកម្មក្នុង និងក្រៅប្រទេស ព្រមទាំងសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជាសេវា

ទូរគមនាគមន៍ អគ្គិសនី និងទឹក ជាដើម។ លើសពីនេះ, *ត្រូវលុបបំបាត់ការខ្ជះខ្ជាយចំណាយ ឬបំប៉ោងចំណាយលើការរៀបចំកិច្ចប្រជុំ សិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ ការតាំងពិព័រណ៍*។ កិច្ចប្រជុំពាក់ព័ន្ធនឹងអាស៊ាន គឺអនុញ្ញាតសម្រាប់តែកិច្ចប្រជុំដែលត្រូវវេន, ចំពោះកិច្ចប្រជុំដែលមិនចំវេនគឺត្រូវសុំគោលការណ៍អនុញ្ញាតពីប្រមុខរាជរដ្ឋាភិបាលជាមុនសិន។ ចំពោះកិច្ចប្រជុំ ឬសិក្ខាសាលាដែលគ្រោងក្នុងថវិកា ត្រូវបង្ហាញពីភាពចាំបាច់ និងភាពសមរម្យនៃការរៀបចំទាំងក្នុងទំហំ និងតម្លៃ។

- ត្រូវពិនិត្យឡើងវិញ និងត្រូវកាត់ចេញនូវមុខចំណាយទាំងឡាយណាដែលមានតម្រូវការសម្រាប់តែអនុវត្តក្នុងឆ្នាំ ២០២៥ ហើយលែងត្រូវការក្នុងឆ្នាំ ២០២៦ ឬសកម្មភាពការងារដែលនឹងត្រូវបញ្ចប់ក្នុងឆ្នាំ ២០២៥។ លើសពីនេះ, ត្រូវកាត់ចេញនូវទំហំចំណាយនៃសកម្មភាពការងារមួយចំនួនដែលត្រូវបានវាយតម្លៃថា លែងមានសារៈសំខាន់។ ក្នុងន័យនេះ, ថវិកាដែលកាត់ចេញពីមុខចំណាយ ឬសកម្មភាពការងារដែលត្រូវបានបញ្ចប់ មិនមែនជាកម្មវត្ថុនៃការវិភាជឡើងវិញជាស្វ័យប្រវត្តិនោះទេ លុះត្រាតែមានសកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយ ថ្មីដែលមានការសម្រេចច្បាស់លាស់ពីរាជរដ្ឋាភិបាលជាយថាហេតុ ដែលត្រូវអនុវត្ត និងដែលត្រូវបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៦-២០២៨ និងមានយុត្តការណ៍អំពីភាពចាំបាច់ និងបន្ទាន់ ព្រមទាំងមានការពន្យល់ និងផ្តល់អំណះអំណាងច្បាស់លាស់ និងត្រឹមត្រូវ ដោយភ្ជាប់មកជាមួយនូវគម្រោងចំណាយលម្អិត ច្បាស់លាស់ ទើបចាត់ទុកជាកម្មវត្ថុនៃការត្រួតពិនិត្យ និងពិភាក្សាអំពីលទ្ធភាពថវិកា។

- ចំពោះតម្រូវការចំណាយបន្ថែម លើសពីកញ្ចប់ពិតានចំណាយគោលដែលផ្តល់ជូនក្រសួង ស្ថាប័ននីមួយៗ គឺត្រូវឆ្លងការពិភាក្សាថវិកាកម្រិតបច្ចេកទេស និងពិនិត្យសម្រេចនៅក្នុងការពិភាក្សាថវិកាកម្រិតថ្នាក់ដឹកនាំ, ឬក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងស្នើសុំការសម្រេច ឬ ស្នើសុំការសម្រេចឡើងវិញពីប្រមុខរាជរដ្ឋាភិបាល បន្ទាប់ពីមានឯកសារទស្សនាទាន យុត្តការណ៍ស្តីពីគោលនយោបាយ និងកម្មវិធី ឬមុខសញ្ញាចំណាយ និងតម្លៃច្បាស់លាស់។

- *សម្រាប់ក្រសួង ស្ថាប័ន និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានភារកិច្ចប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំដាក់ចេញវិធានការដាក់ស្តែងបន្ថែម សម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ព្រោះលទ្ធផល និងការបង្ហាញពីកិច្ចខិតខំក្នុងការប្រមូលចំណូល គឺជាកម្មវត្ថុនៃការរឹតត្បិត ឬការលើកទឹកចិត្តចំណាយ នៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ*។

- ត្រូវបង្កើនវិមជ្ឈការនៃការផ្ទេរចំណាយជាប្រចាំសម្រាប់កិច្ចដំណើរការរដ្ឋបាល និងសោហ៊ុយបេសកកម្មក្នុងប្រទេស និងក្រៅប្រទេស ជាដើម ទៅឱ្យតាមអង្គភាពថវិកា ឱ្យបានច្រើនក្នុងកម្រិតអតិបរមា។

- ដើម្បីអនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ, ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវរៀបចំជាផែនការសកម្មភាពការងារទៅតាមកម្មវិធី និងស្នើសុំថវិកាក្នុងក្របខ័ណ្ឌនៃកញ្ចប់ថវិការួមប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ននីមួយៗ។ ទន្ទឹមនេះ, ក្រសួង ស្ថាប័ននីមួយៗ ត្រូវគិតគូរពិចារណាដាក់បញ្ចូលទៅក្នុងគម្រោងថវិកានូវបណ្តាអាទិភាពបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដូចមានចែងក្នុងផែនការស្តីពីការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (២០២០) និងយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

នឹងពិនិត្យ និងវិភាជថវិកាជូនក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយផ្អែកលើមូលដ្ឋាននៃភាពចាំបាច់ និងប្រសិទ្ធភាព ព្រមទាំងស្របតាមលទ្ធភាពថវិកាជាក់ស្តែង។

- ក្រសួង ស្ថាប័នត្រូវពិនិត្យលទ្ធភាពក្នុងការផ្ទេរធនធានថវិកាពីកម្មវិធីមួយ ទៅកម្មវិធីមួយទៀត ឬពីអង្គភាពថវិកាមួយ ទៅអង្គភាពថវិកាមួយទៀត នៅផ្ទៃក្នុងក្រសួង ស្ថាប័ននីមួយៗឱ្យអស់លទ្ធភាព ព្រមជាមួយនឹងការថ្លឹងថ្លែងតុល្យភាពនៃការបែងចែកធនធានរវាងអង្គភាពថវិកានីមួយៗ ក្នុងក្របខ័ណ្ឌនៃកញ្ចប់ពិតានចំណាយគោលរបស់ខ្លួន និងត្រូវចៀសវាងការបំប៉ោងចំណាយ ដោយមូលហេតុនៃការអនុវត្តថវិកាសមិទ្ធកម្ម។

- ជាមួយគ្នានេះដែរ ដើម្បីបង្កើនប្រសិទ្ធភាពចំណាយនៅដំណាក់កាលរៀបចំ និងចរចាថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឱ្យកាត់ចេញនូវប្រភេទចំណាយមិនប្រចាំដែលជាថវិកាផ្ទៃក្នុងក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)។ ទំហំថវិកាដែលនៅសល់ក្នុងក្របខ័ណ្ឌពិតាននេះ អាចជាកម្មវត្ថុនៃការវិភាជសម្រាប់កែលម្អ ឬបង្កើនប្រសិទ្ធភាពនៃកម្មវិធីដែលមានស្រាប់ ឬសម្រាប់កម្មវិធី បម្រើឱ្យគោលនយោបាយថ្មី នៅក្នុងក្រសួង ស្ថាប័នដដែល ឬទៅក្រសួង ស្ថាប័នមួយទៀត។

គ-ចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ (ជំពូក ២១) និងចំណាយជួសជុលនិងថែទាំផ្លូវថ្នល់ និងធារាសាស្ត្រ (ជំពូក ៦១) ត្រូវបន្តអនុវត្តតាមនីតិវិធីដែលបាននិងកំពុងអនុវត្តជាធរមាន និង តាមគោលការណ៍ ដូចខាងក្រោម៖

- ក្នុងចំណោមក្រសួងទាំង ១១ ដែលនឹងទទួលបានការវិភាជថវិកាក្នុងច្បាប់ហិរញ្ញវត្ថុផ្ទាល់, មានក្រសួងចំនួន ៨ រួមមាន៖ ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងធនធានទឹកនិងឧតុនិយម, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល, ក្រសួងមហាផ្ទៃ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគ ជាមួយនឹងគម្រោងចំណាយចរន្តនៅកម្រិតកម្មវិធី និងអនុកម្មវិធី។ ក្នុងន័យនេះ ក្រសួងទាំង ៨ នេះ ត្រូវរៀបចំបញ្ជីគម្រោងអាទិភាពប្រចាំឆ្នាំឱ្យបានទាន់ពេល ដើម្បីស្នើសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាលជាមុន សម្រាប់ជាមូលដ្ឋាននៃការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ ដោយឡែក ក្រសួង ៣ ទៀត រួមមាន៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ត្រូវចាប់ផ្តើមបន្តសាកល្បងធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគជាមួយនឹងគម្រោងចំណាយចរន្ត នៅកម្រិតកម្មវិធីនិងអនុកម្មវិធីផងដែរ។ ចំពោះការកំណត់អាទិភាព និងជ្រើសរើសគម្រោងដែលក្រសួងនីមួយៗបានស្នើឡើង គឺជាកម្មវត្ថុនៃការពិនិត្យពិភាក្សាតាមយន្តការ គណៈកម្មការ ឬក្រុមការងារអន្តរក្រសួង ដោយផ្អែកទៅតាមអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងគោលការណ៍កំណត់អាទិភាពគម្រោងដែលមានចែងនៅក្នុងសារាចរនេះសម្រាប់ជាមូលដ្ឋានស្នើសុំការពិនិត្យនិងសម្រេចពីប្រមុខរាជរដ្ឋាភិបាល។

- សម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីទទួលបានថវិកាពីកញ្ចប់ថវិកាមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល ត្រូវសិក្សានិងលើកគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យ និងរៀបចំអាទិភាវូបនីយកម្មគម្រោង គោរពស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាល តាមលទ្ធភាពថវិកាប្រចាំឆ្នាំ។ គម្រោងវិនិយោគដែលអាចស្នើឡើង ដើម្បីពិភាក្សាត្រូវបំពេញតាមគោលការណ៍ និងលក្ខខណ្ឌតម្រូវដែលមានកំណត់នៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។
- ការគ្រោងចំណាយសម្រាប់គម្រោងវិនិយោគសាធារណៈ និងគម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ (ផ្លូវថ្នល់ និងធារាសាស្ត្រ) ត្រូវបន្តអនុវត្តតាមគោលការណ៍កំណត់អាទិភាពសំខាន់ៗដូចខាងក្រោម៖
  - <u>វិស័យផ្លូវថ្នល់</u>
    - ✓ អាទិភាពទី ១៖ គម្រោងថែទាំ ជួសជុល ស្តារ និងលើកកម្រិតគុណភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ដែលមានស្រាប់ តាមសមត្ថកិច្ចទទួលខុសត្រូវរៀងៗខ្លួនដើម្បីថែរក្សាសមិទ្ធផលឱ្យមានចីរភាព ធានាប្រសិទ្ធភាពក្នុងការប្រើប្រាស់ និងទ្រទ្រង់កំណើនសេដ្ឋកិច្ច។
    - ✓ អាទិភាពទី ២៖ គម្រោងថ្មីដែលមានការសម្រេចពីប្រមុខរាជរដ្ឋាភិបាល។
    - ✓ អាទិភាពទី ៣៖ គម្រោងពហុឆ្នាំដែលត្រូវសាងសង់បន្ត ឬបញ្ចប់។ ក្នុងករណីចាំបាច់ត្រូវពិនិត្យ វាយតម្លៃឡើងវិញនូវប្រសិទ្ធភាព និងអត្ថប្រយោជន៍នៃគម្រោង។
    - ✓ អាទិភាពទី ៤៖ គម្រោងថ្មីដែលមានការសិក្សាច្បាស់លាស់ និងមានផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច សង្គម និងនយោបាយ។
  - <u>វិស័យធារាសាស្ត្រ</u>
    - ✓ អាទិភាពទី ១៖ គម្រោងថែទាំ ជួសជុល ស្តារ និងលើកកម្រិតគុណភាពហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ដើម្បីថែរក្សាសមិទ្ធផលឱ្យមានចីរភាព, ធានាបាននូវប្រសិទ្ធភាព ក្នុងការប្រើប្រាស់ និងទ្រទ្រង់កំណើនសេដ្ឋកិច្ច។
    - ✓ អាទិភាពទី ២៖ គម្រោងពហុឆ្នាំដែលត្រូវសាងសង់បន្ត ឬបញ្ចប់ ដើម្បីបង្កប់ប្រសិទ្ធភាពសេដ្ឋកិច្ច សង្គម។
    - ✓ អាទិភាពទី ៣៖ គម្រោងថ្មីដែលមានការសិក្សាច្បាស់លាស់ និងមានផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច សង្គម និងនយោបាយ។
  - <u>វិស័យអប់រំ</u>
    - ✓ អាទិភាពទី ១៖ គម្រោងដែលមានការសម្រេចច្បាស់លាស់ពីប្រមុខរាជរដ្ឋាភិបាល។
    - ✓ អាទិភាពទី ២៖ គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធអប់រំ ដែលគាំទ្រដល់ការអនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាល ក៏ដូចជាការកែលម្អការលើកកម្ពស់វិស័យអប់រំ ជាពិសេសសាងសង់អគារសិក្សា ដោយឈរលើមូលដ្ឋាននៃការសិក្សា និងវាយតម្លៃច្បាស់លាស់អំពីតម្រូវការជាអាទិភាព។

- <u>វិស័យសុខាភិបាល</u>
  - ✓ អាទិភាពទី ១៖ គម្រោងជួសជុល សាងសង់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល និងបរិក្ខារពេទ្យ ដើម្បីថែរក្សាសមិទ្ធផលឱ្យមានចីរភាព និងជានាប្រសិទ្ធភាពក្នុងការប្រើប្រាស់។
  - ✓ អាទិភាពទី ២៖ គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល ជាពិសេសការសាងសង់មន្ទីរពេទ្យ, មណ្ឌលសុខភាព និងការបំពាក់បរិក្ខារពេទ្យតាមមូលដ្ឋានសុខាភិបាល សំដៅគាំទ្រការអនុវត្តផែនការគន្លឹះរបស់រាជរដ្ឋាភិបាល ក៏ដូចជាការកែលម្អការលើកកម្ពស់វិស័យសុខាភិបាល ដោយឈរលើមូលដ្ឋាននៃការសិក្សា និងវាយតម្លៃច្បាស់លាស់អំពីតម្រូវការជាអាទិភាព។
- <u>វិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ</u>
  - ✓ អាទិភាពទី ១៖ គម្រោងស្ថាបនាប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់។
  - ✓ អាទិភាពទី ២៖ គម្រោងស្ថាបនាប៉ុស្តិ៍នគរបាលការពារព្រំដែន។
  - ✓ អាទិភាពទី ២៖ គម្រោងជួសជុលនិងស្ថាបនាពន្ធនាគារ។
  - ✓ អាទិភាពទី ៣៖ គម្រោងគាំទ្រនានាលើវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈតាមការចាំបាច់។
- <u>វិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ</u>
  - ✓ អាទិភាពទី ១៖ គម្រោងជួសជុល ស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេសដើម្បីជានាប្រសិទ្ធភាពក្នុងការប្រើប្រាស់ ការគាំទ្រតម្រូវការទីផ្សារការងារ និងលើកកម្ពស់ផលិតកម្ម។
  - ✓ គម្រោងពហុឆ្នាំដែលត្រូវសាងសង់បន្ត ឬបញ្ចប់ ដើម្បីបង្កប់ប្រសិទ្ធភាពសេដ្ឋកិច្ច សង្គម។
  - ✓ អាទិភាពទី ២៖ គម្រោងបំពាក់ឧបករណ៍ និងសម្ភារៈបច្ចេកទេសចាំបាច់លើវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ។
  - ✓ គម្រោងថ្មីដែលមានការសិក្សាច្បាស់លាស់ និងមានផលប្រយោជន៍ចំពោះវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈច្បាស់លាស់។
- <u>វិស័យទឹកស្អាត៖</u>
  - ✓ អាទិភាពទី ១៖ គម្រោងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបណ្តាញចែកចាយទឹកស្អាត។
  - ✓ អាទិភាពទី ២៖ គម្រោងបំពាក់ឧបករណ៍ពិសោធន៍ និងសម្ភារៈបច្ចេកទេស។

ឃ-ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍ៖ ក្រសួង ស្ថាប័នចំនួន ១០ ដែលនឹងទទួលបាននូវការវិភាជថវិកាជំពូក ២១ (គម្រោងវិនិយោគផ្ទាល់) ព្រមទាំងក្រសួង ស្ថាប័នដទៃទៀត ដែលបាននិងកំពុងទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ ឬគ្រោងនឹងទទួលបានហិរញ្ញប្បទាន ស្របតាមកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (២០២៦-២០២៨) ត្រូវគ្រោងឱ្យបានត្រឹមត្រូវទៅតាមកិច្ចព្រមព្រៀង ឬអនុស្សរណៈនៃការយោគយល់គ្នា ឬការសន្យាតាមរយៈយន្តការផ្សេងៗ។

**៣០-ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ៖** ក្នុងគោលបំណងលើកកម្ពស់គុណភាព និងអនុលោមភាពនៃការរៀបចំ និងការអនុវត្តផែនការលទ្ធកម្មប្រចាំឆ្នាំ ក៏ដូចជាដើម្បីធានាឱ្យការរៀបចំថវិកាប្រចាំឆ្នាំកាន់តែមានប្រសិទ្ធភាព **ជាពិសេសធានាឱ្យថវិកាអាចអនុវត្តបានភ្លាមចាប់ពីខែ មករា នៃឆ្នាំសារពើពន្ធ** គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំសម្រាប់មុខចំណាយដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្ម ដោយផ្អែកលើកញ្ចប់ថវិកាដែលគ្រោងស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដូច្នេះ, ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវភ្ជាប់ផែនការលទ្ធកម្មមកជាមួយនឹងសំណើគម្រោងថវិកាឆ្នាំ ២០២៦ របស់ខ្លួនចំនួន**ពីរច្បាប់** (១ ច្បាប់បញ្ជូនទៅអគ្គនាយកដ្ឋានថវិកា និង ១ ច្បាប់ទៀតបញ្ជូនទៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) សម្រាប់ការប្រជុំពិភាក្សាកម្រិតបច្ចេកទេស និងការចរចាកញ្ចប់ថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង។ គោលការណ៍ និងនីតិវិធីនៃការរៀបចំផែនការលទ្ធកម្ម ត្រូវអនុលោមតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៧ ស្តីពីការរៀបចំផែនការលទ្ធកម្ម។

បន្ទាប់មក, ផ្អែកលើស្មារតី និងលទ្ធផលនៃការចរចាកញ្ចប់ថវិកា ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវកែសម្រួលសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំឱ្យមានសង្គតិភាពជាមួយនឹងកញ្ចប់ថវិកាដែលទទួលបាននៅក្នុងកិច្ចប្រជុំចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង រួចបញ្ជូនសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំដែលបានកែសម្រួលរួចនេះ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **យ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី ៣ ខែ វិច្ឆិកា** ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានពេលគ្រប់គ្រាន់សម្រាប់ពិនិត្យ និងអនុម័តឱ្យបានមុនថ្ងៃទី ៣១ ខែ ធ្នូ មុនឆ្នាំអនុវត្តថវិកា។

**៣១-ការរៀបចំផែនការរជ្ជទេយ្យបុរេប្រទាន៖** ត្រូវធ្វើឡើងដំណាលគ្នានឹងការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ សម្រាប់ពិនិត្យនិងពិភាក្សាក្នុងកិច្ចប្រជុំការពារគម្រោងថវិកាប្រចាំឆ្នាំ។ ក្នុងអំឡុងពេលប្រជុំការពារគម្រោងថវិកា មិនតម្រូវឱ្យពិនិត្យមើលលម្អិតលើតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានទេ ប៉ុន្តែក្រសួង ស្ថាប័ន, មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវធានាថាមុខចំណាយថវិកាដែលត្រូវយកមករៀបចំតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន មិនត្រូវត្រួតគ្នានឹងមុខចំណាយថវិកាដែលត្រូវបានគ្រោងទុកសម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈ, តាមនីតិវិធីទូទាត់ត្រង់ និង តាមនីតិវិធីចំណាយផ្សេងទៀតទេ។

**៣២-ការផ្តល់របាយការណ៍សមិទ្ធកម្ម៖** ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដែលអនុវត្តថវិកាសមិទ្ធកម្ម ត្រូវតែផ្តល់របាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាឆ្នាំ ២០២៤ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្ត ហើយ

ក៏ជាកម្មវត្ថុសម្រាប់ការលើកទឹកចិត្ត ឬការកាត់បន្ថយគម្រោងចំណាយឆ្នាំ ២០២៦ ផងដែរ។ *នៅពេលពិភាក្សា និងចរចាថវិកា ក្រសួង ស្ថាប័ននីមួយៗត្រូវតែរៀបចំជាបទបង្ហាញអំពីរបាយការណ៍សមិទ្ធកម្មឆ្នាំ ២០២៤ របាយការណ៍សមិទ្ធកម្មពាក់កណ្តាលឆ្នាំ ២០២៥ និងការគ្រោងលទ្ធផលរំពឹងទុកសម្រាប់ឆ្នាំ ២០២៦។*

៣៣-ទន្ទឹមនេះ, ក្នុងគោលដៅដើម្បីធានាបាននូវការអនុវត្តជាមូលដ្ឋាននូវថវិកាសមិទ្ធកម្មនៅឆ្នាំ ២០២៦, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងធ្វើការពិភាក្សាចរចាថវិកា ដោយផ្តោតលើ**អភិក្រមចំរុះ ដែលបំពេញគ្នាទៅវិញទៅមក និងមានលក្ខណៈទន់ភ្លន់ គឺៈ តាមរចនាសម្ព័ន្ធកម្មវិធី ដែលរួមមានតាមកម្មវិធី អនុកម្មវិធី និងតាមសកម្មភាពការងារ ឬទៅតាមមុខសញ្ញាចំណាយ** អាស្រ័យលើកត្តាជាក់ស្តែងនៃរចនាសម្ព័ន្ធថវិកាកម្មវិធីរបស់ក្រសួង ស្ថាប័ននីមួយៗ។ អភិក្រមថ្មីនេះ នឹងជួយកាត់បន្ថយបានជាអតិបរមានូវការចរចាថវិកាផ្អែកលើធាតុចូល (Input) ដោយតម្រង់ការពិភាក្សាថវិកាដោយផ្អែកលើសកម្មភាព (Activity) និងធាតុចេញ (Output) ជាសំខាន់វិញ។ ទោះជាយ៉ាងនេះក្តី, ការចរចាដោយផ្អែកលើធាតុចូលក៏នៅតែត្រូវបានគិតគូរលើមុខចំណាយមួយចំនួននៃក្រសួង ស្ថាប័នខ្លះ ដែលត្រូវបានអនុញ្ញាតឱ្យរៀបចំថវិកាសមិទ្ធកម្ម តាមទម្រង់មានលក្ខណៈស្រាល ជាពិសេស ក្រសួង ស្ថាប័ន ស្ថិតក្នុងវិស័យរដ្ឋបាលទូទៅ និងវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។

៣៤-**ការបម្រែបម្រួលនៃការគ្រោងថវិកាតាមកម្មវិធីៈ** ផ្អែកលើមូលដ្ឋាននៃច្បាប់ថវិកាឆ្នាំ ២០២៥ ដែលកំពុងអនុវត្ត, ក្នុងការរៀបចំថវិកាឆ្នាំ ២០២៦, ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ អាចពិនិត្យផងដែរទៅដល់បម្រែបម្រួលនៃថវិកាក្នុងអំឡុងពេលអនុវត្តដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោមៈ

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងអនុវត្ត ដូចជាការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬពីជំពូកមួយទៅជំពូកមួយទៀតផ្ទៃក្នុង ឬពីកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៅកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៀត ដែលធ្វើឱ្យឥណទានដើមឆ្នាំរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ មានការប្រែប្រួល,
- ការផ្ទេរឥណទានថវិកាបន្ថែមសម្រាប់ផលប្រយោជន៍របស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

៣៥-អនុវត្តតាមប្រកាសលេខ ៣៥៤ សហវ.ប្រក ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០២២ **ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិការគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង**, នៅឆ្នាំ ២០២៥ នេះ, ក្រសួង ស្ថាប័ន ចំនួន ១៤ រួមមានៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងមហាផ្ទៃ (ផ្នែកសន្តិសុខសាធារណៈ), ក្រសួងសុខាភិបាល, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងធម្មការ និងសាសនា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងកិច្ចការនារី, ក្រសួងរ៉ែ និងថាមពល, ក្រសួងទេសចរណ៍, ក្រសួងអភិវឌ្ឍន៍ជនបទ, រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, ក្រសួងការពារជាតិ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានជ្រើសរើសឱ្យអនុវត្តសាកល្បងនូវគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង។ សម្រាប់ការគ្រោងថវិកាឆ្នាំ ២០២៦, ក្រសួង ស្ថាប័នចំនួន ១០ រួមមានៈ ក្រុមប្រឹក្សាធម្មនុញ្ញ, ក្រសួងព័ត៌មាន, ក្រសួងពាណិជ្ជកម្ម, ក្រសួងបរិស្ថាន, ក្រសួងប្រៃសណីយ៍ និងទូរគមាគមន៍,

ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, អាជ្ញាធរសេវនកម្មជាតិ, អង្គភាពប្រឆាំងអំពើពុករលួយ និងរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ត្រូវបានជ្រើសរើសបន្ថែមសម្រាប់ការ-អនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង ដោយតម្រូវឱ្យផ្លាស់ប្តូរការគ្រោងថវិការបស់ខ្លួនលើមុខចំណាយជាសារវន្តមួយចំនួន (ឧ. ចំណាយទិញរថយន្ត និងចំណាយទិញទោចក្រយានយន្ត) ដែលមានចរិតជាចំណាយមូលធន ដោយប្តូរពីការគ្រោងក្នុងជំពូក ៦០ និងជំពូក ៦១ នៃថវិកាចំណាយចរន្ត ទៅគ្រោងក្នុងជំពូក ២០, ជំពូក ២១ ឬជំពូក ២៣ នៃចំណាយមូលធនវិញ ស្របតាមវិធីសាស្ត្រដែលមានចែងលម្អិតក្នុងគោលការណ៍ណែនាំនេះ។

៣៦-ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវពង្រឹងតួនាទីក្រុមការងារថវិការបស់ខ្លួន និងត្រូវផ្តល់កិច្ចសហការគ្នាទៅវិញទៅមកជាប្រចាំឱ្យបានពេញលេញក្នុងកម្រិតបច្ចេកទេស ជាមួយក្រុមការងារថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) សំដៅបង្កើនប្រសិទ្ធភាព និងភាពទាន់ពេលនៃការរៀបចំថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ននីមួយៗ។

## ៤.៣-កាលវិភាគនៃការរៀបចំគម្រោងចំណូល-ចំណាយថវិកាឆ្នាំ ២០២៦

៣៧-រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលនូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦។ ក្នុងកិច្ចដំណើរការនេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការរបស់រាជរដ្ឋាភិបាល ត្រូវដឹកនាំការរៀបចំ ដើម្បីធានាឱ្យសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៦ និងសំណុំឯកសារពាក់ព័ន្ធ ត្រូវបានអនុម័ត និងប្រកាសឱ្យប្រើដោយព្រះរាជក្រម ឱ្យបានចប់សព្វគ្រប់យ៉ាងយូរត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ស្របតាមមាត្រា ៥១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៣។ ដូចនេះ, ឯកសារផែនការយុទ្ធសាស្ត្រថវិកា **ឆ្នាំ ២០២៦-២០២៨ និងគម្រោងចំណូល-ចំណាយថវិកាឆ្នាំ ២០២៦** ដែលក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវដាក់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាឯកសារចាំបាច់មិនអាចខ្វះបានសម្រាប់**ការចរចាថវិកាទាំងកម្រិតបច្ចេកទេស និងការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង** ដើម្បីធ្វើយុត្តិកម្មកញ្ចប់ថវិការបស់ខ្លួន។

ក្នុងន័យនេះ, ក្នុងករណីដែលក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធណាមួយមិនបានបំពេញ និងផ្តល់ព័ត៌មានគ្រប់គ្រាន់ទៅតាមគោលការណ៍ និងតារាងគំរូ ដែលភ្ជាប់ជាមួយសារាចរនេះ នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនោះឱ្យបានទាន់ពេល ដើម្បីធ្វើការបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការយកមូលដ្ឋានត្រឹមកម្រិតពិតានចំណាយគោល ដោយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូកខាងលើ សម្រាប់កំណត់គម្រោងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនោះ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦ ឱ្យបានទាន់ពេល និងគ្រប់ជ្រុងជ្រោយ។

## ៥-សេចក្តីសន្និដ្ឋាន

៣៨-សារាចរនេះ ត្រូវបានរៀបចំឡើង ដោយផ្អែកលើគោលបំណងចម្បង ដែលត្រូវបានកំណត់ក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ ពោលគឺ *«ដើម្បីរក្សាលំនឹងជីភាពប្រជាជន និង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការពង្រឹងប្រសិទ្ធភាព និងធានាចីរភាពហិរញ្ញវត្ថុសាធារណៈ សំដៅលើកកម្ពស់សមធម៌សង្គម ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងជំរុញការអភិវឌ្ឍឆ្ពោះទៅចក្ខុវិស័យកម្ពុជា ២០៥០»*។ យ៉ាងណាមិញ, ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ បានផ្តល់ជាទស្សនវិស័យអំពីនិន្នាការចំណូល និងចំណាយថវិកាជាតិ ក៏ដូចជាលំហថវិកា ដែលអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចមានលទ្ធភាពដោះស្រាយបាននូវតម្រូវការចំណាយជាយុទ្ធសាស្ត្រ និងជាអាទិភាពសម្រាប់រយៈពេលខ្លី និងមធ្យម ក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជាខ្លាំងពីកត្តាខាងក្រៅ ជាពិសេសដោយសារការដាក់ចេញនូវវិធានការគោលនយោបាយពន្ធគយបដិការរបស់សហរដ្ឋអាម៉េរិក។ សំខាន់ជាងនេះទៀត, ការផ្តល់ពិតានចំណាយគោលសម្រាប់គ្រប់ក្រសួង ស្ថាប័ន និងពិតានចំណាយគោលសម្រាប់ឧបត្ថម្ភធនដល់គ្រឹះស្ថានសាធារណៈរដ្ឋបាល បានផ្តល់ជាព័ត៌មានដល់គ្រប់ក្រសួង ស្ថាប័ន អំពីភាពអាចប៉ាន់ប្រមាណបាននៃធនធានថវិកាដែលអាចទទួលបាន, ក្នុងបរិការណ៍បច្ចុប្បន្នដែលប្រកបដោយហានិភ័យខ្ពស់នេះ, សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៦-២០២៨ និងការរៀបចំគម្រោងថវិកាឆ្នាំ ២០២៦ ព្រមជាមួយនឹងការផ្តល់នូវការណែនាំអំពីគោលការណ៍ និងបច្ចេកទេសនៃការគ្រោងចំណូល និងចំណាយ ជាពិសេសផ្តល់លទ្ធភាពដល់គ្រប់ក្រសួង ស្ថាប័ន អាចធ្វើអាទិភាវូបនីយកម្មមុខចំណាយ និងធ្វើវិចារណកម្មចំណាយជាមួយនឹងធនធានដែលមាន ដើម្បីធានាជោគជ័យក្នុងការអនុវត្តគោលនយោបាយគន្លឹះនានារបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល នឹងបន្តតាមដានដោយយកចិត្តទុកដាក់លើការវិវត្ត និងវាយតម្លៃសភាពការណ៍ឡើងវិញ មុនពេលរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦ ដើម្បីកែសម្រួលក្របខ័ណ្ឌនេះតាមការចាំបាច់ និងតាមការណ៍ជាក់ស្តែង ជាពិសេសក្នុងកាលៈទេសៈដែលសភាពការណ៍មិនអំណោយផល។

៣៩-ទោះជាយ៉ាងណាក្តី, ដើម្បីឱ្យគោលដៅទាំងឡាយដែលបានដាក់ចេញក្នុងសារាចរនេះ អាចអនុវត្តសម្រេចបានជោគជ័យ ថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័ន និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ចាំបាច់ត្រូវខិតខំថែមទៀតប្រកបដោយឆន្ទៈប្តូរផ្តាច់ ជាពិសេសត្រូវតែផ្លាស់ប្តូរឥរិយាបទ និងផ្នត់គំនិតក្នុងការរៀបចំថវិកា ដោយខិតខំគោរពឱ្យបានខ្ជាប់ខ្ជួនតាមក្របខ័ណ្ឌ ព្រមទាំងគោលការណ៍ និងបច្ចេកទេសទាំងឡាយ ទាំងផ្នែកចំណូល និងផ្នែកចំណាយ ដែលកំណត់ដោយសារាចរនេះ។ ទន្ទឹមនេះ, គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវបន្តជំរុញការលើកកម្ពស់អភិបាលកិច្ចល្អក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ ដើម្បីមិនត្រឹមតែអាចបង្កើនសក្តានុពលនៃតួនាទីរបស់ថវិកា ឱ្យទៅជាឧបករណ៍សម្រាប់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ថែមទាំងអាចធ្វើជាចន្ទល់ដ៏រឹងមាំសម្រាប់ទ្រទ្រង់ដល់ការដ្ឋានកម្មវិធីកែទម្រង់ដទៃទៀតផងដែរ។

៤០-ពេលទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវរៀបចំជាការប្រញាប់នូវ *ផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០២៦-២០២៨ ដែលមានវិសាលភាពគ្របដណ្តប់ទាំងផែនការយុទ្ធសាស្ត្រថវិការបស់មន្ទីរជំនាញរាជធានី ខេត្ត,*

*គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ (សម្រាប់មុខងារប្រេគល់មានភ្ជាប់លក្ខខណ្ឌ ក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ), និងគម្រោងចំណូល-ចំណាយឆ្នាំ ២០២៦* និងផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ចំនួនពីរច្បាប់ **យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០២៥ ជាកំហិត** ដើម្បីមានពេលគ្រប់គ្រាន់សម្រាប់ការពិភាក្សាថវិកាកម្រិតបច្ចេកទេស ចាប់ពីថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០២៥ និង និងការពិភាក្សាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០២៥។ ក្នុងការអនុវត្តសារាចរនេះ, ប្រសិនបើក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា)។

៤១-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រប់ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តសារាចរនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៩រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- គ្រប់មន្ទីរជំនាញរាជធានី ខេត្ត
- គ្រប់គណៈអភិបាលក្រុង ស្រុក
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ